លេខ ២ ខែ កុម្ភៈ ឆ្នាំ១៩៩០

រដ្ឋកិច្ច

រួមមាន :

- ច្បាប់
- ក្រឹត្យ-ច្បាប់
- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ
- សារាចរណែនាំ

ផ្សាយចេញពីខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីជារៀងរាល់ខែ

មាតិកា

ទំព័រ

I – ក្រុមប្រឹក្សារដ្ឋ

ក្រឹត្យ

១១-០២-៩០ ក្រឹត្យលេខ ១២ ក្រ ស្ដីពីការប្រកាសអោយប្រើច្បាប់ ស្ដីពីការកែប្រែការចាត់តាំងនិងភារកិច្ចរបស់អង្គភាពនាយកដ្ឋានការកោសល្យ ២១

II – ក្រុមប្រឹក្សារដ្ឋមន្ត្រី

១ – អនុក្រឹត្យ

១៥-០២-៩០ អនុក្រឹត្យលេខ ០៨ អនក្រ ស្ដីពីឯកសណ្ឋាន សញ្ញាសំគាល់ និង សញ្ញាបាត់ស័ក្តិ ឯកសណ្ឋានសំរាប់ផ្នែកបញ្ជូនរបស់នគរបាល — ប្រជាជន ២៣

១៧-០២-៩០ អនុក្រឹត្យលេខ ០៩ អនក្រ ស្ដីពីការតម្លើង និងសមត្ថភាពយោធារបស់ នគរបាល ប្រជាជន ២៩

២១-០២-៩០ អនុក្រឹត្យលេខ ០៩ អនក្រ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គ- នាយកដ្ឋានទេសចរណ៍ ៣២

២- សេចក្ដីសំរេច

១៥-០២-៩០ សេចក្ដីសំរេចលេខ ២៨ សសរ ស្ដីពីការចាត់តាំងមន្ត្រីទទួលបន្ទុកសារាចរ ជំនួសសេចក្ដីសំរេចលេខ ១៨ សសរ ចុះថ្ងៃទី ០៣ (ខែមករា) ឆ្នាំ១៩៩០ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ៣១

២៣-០២-៩០ សេចក្ដីសំរេចលេខ ២៩ សសរ ស្ដីពីការកំណត់ផែនការចំណូល ចំណាយថវិកាបណ្ដោះអាសន្នសំរាប់ឆ្នាំ ១៩៩០ ៣៦

៣- សេចក្ដីណែនាំ

២៦-០២-៩០ សេចក្ដីណែនាំលេខ ០១ សណន ស្ដីពីការបង្កើនប្រសិទ្ធភាពគ្រប់គ្រង ផលិតកម្ម និងផលិតផលបានលើសផែនការ ៤៥

ញ – ការងារបណ្ដាក្រសួង

១ – ក្រសួងពាណិជ្ជកម្ម

សេចក្ដីសំរេច

១២-០២-៦០ សេចក្ដីសំរេចលេខ ០៨១ កណ គបក សសរ ស្ដីពីថ្លៃទិញអង្ករមេប្រហារ
បន្ថែម និងផ្ទាត់ណើកទឹកចិត្តសំរាប់រដូវឆ្នាំ ១៩៥៩ - ១៩៦០ ៥៥

១៥-០២-៦០ សេចក្ដីសំរេចលេខ ១០៧ កណ គបក សសរ ស្ដីពីថ្លៃលក់ប្រេងសាំង
នៅក្នុងក្រៅនគរ ៦០

៣ – ក្រសួងកសិកម្ម

សេចក្ដីសំរេច

២៨-០២-៦០ សេចក្ដីសំរេចលេខ ០៣៥ សសរ កសក ស្ដីពីថ្លៃលក់ឧបករណ៍ និង
សម្ភារៈកសិកម្ម ៦២

២៧-០២-៦០ សេចក្ដីសំរេចលេខ ០៣៥ សសរ កសក ស្ដីពីថ្លៃលក់ថ្នាំព្យាបាលសត្វ ៦៣

+ + + +

I - ក្រុមប្រឹក្សារដ្ឋ

ក្រឹត្យ

ក្រឹត្យ លេខ ១២ ក្រ

ក្រុមប្រឹក្សារដ្ឋ

នៃ

រដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ ស្ដីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

សំរេច

ប្រកាសអោយប្រើច្បាប់ ស្ដីពីការកែប្រែ ការចាត់តាំង តួនាទី និង ភារកិច្ចរបស់អគ្គនាយកដ្ឋានចំការកៅស៊ូ ដែលរដ្ឋសភា នៃរដ្ឋកម្ពុជាបានអនុម័តនៅថ្ងៃទី ៣១ ខែមករា ឆ្នាំ ១៩៩០ នាសម័យប្រជុំសាមញ្ញលើកទី ១៨ នីតិកាលទី ១ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩០

ជ. ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

ហេង សំរិន

II – ក្រុមប្រឹក្សារដ្ឋមន្ត្រី

១ – អនុក្រឹត្យ

ភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩០

អនុក្រឹត្យ លេខ ០៤ អនក្រ

ស្តីពី

ទង់នគរបាលប្រជាជន សញ្ញាសំគាល់ និងសញ្ញាឋានន្តរសក្តិ

ឯកសណ្ឋានសំរាប់ថ្ងៃបុណ្យរបស់នគរបាលប្រជាជន

ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

- បានឃើញច្បាប់ស្តីអំពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

- បានឃើញក្រឹត្យ - ច្បាប់លេខ ៣៩ ក្រ.ច ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋ ស្តីពីការកែប្រែអង្គការចាត់តាំង តួនាទី និងភារកិច្ចរបស់ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញក្រឹត្យ - ច្បាប់លេខ ៤០ ក្រ.ច ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋ ស្តីពីឋានន្តរសក្តិនគរបាលប្រជាជន

- បានឃើញក្រឹត្យ - ច្បាប់លេខ ០៧ ក្រ.ច ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៨២ ស្តីពីសមត្ថកិច្ច និង នីតិវិធីនៃការធ្វើច្បាប់ និង បទបញ្ជា

- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ .– ទង់របស់កងកម្លាំងនគរបាលប្រជាជន រាងបួនជ្រុងទ្រវែង ទទឹងស្មើនឹង ២ ភាគ ៣ នៃបណ្តោយ ផ្ទៃពណ៌ក្រហម នៅចំកណ្តាលមានរូបប្រាសាទ

កំពូលប្រាំរលេចក្បាច់ក្បាច់ពណ៌លឿងផ្នែកខាងលើនៃជ្រុងខាងឆ្វេងមានចារឹកអក្សរ " ប៉ុស្ដិ៍ឈ្មោះ " និងនៅតាមជាយជុំវិញមានរំលេចដោយរំយោលពណ៌លឿង ។

មាត្រា ២ .— ទង់របស់កងកម្លាំងនគរបាលប្រជាជន សំរាប់ប្រើប្រាស់ក្នុងថ្ងៃបុណ្យពិធីប្រជុំសន្និបាត មហាសន្និបាត នៅពេលព្យុហយាត្រា មិទ្ទិញ ថ្ងៃបុណ្យខួបអនុស្សាវរីយ៍ ពេលដែលថ្នាក់ដឹកនាំបក្ស - រដ្ឋ ចុះសួរសុខទុក្ខ ត្រួតពល និងតាំងតំកល់ទុកនៅសារមន្ទីរ អាគារប្រពៃណីរបស់កងកម្លាំងនគរបាលប្រជាជន ។

មាត្រា ៣ .— សញ្ញាសំគាល់នគរបាលដាក់មុខមួក រាងមូលវិជ្ជមាត្រ ៣,៦ សង់ទីម៉ែត្រ ផ្ទៃពណ៌ក្រហមនៅចំកណ្ដាលមានរូបប្រាសាទកំពូលប្រាំពណ៌មាស នៅក្រោមរូបប្រាសាទមានសរសេរអក្សរកាត់ " ន.ប " តំណាងពាក្យ " នគរបាល " អមសងខាងមានកំរងផ្កាស្រូវពណ៌មាសមានគល់បញ្ចូលទៅក្នុងរាក់កណ្ដាលកង់គ្រឿងចក្រ ប្រាំពីរកាំពណ៌មាស ផ្នែកខាងក្រៅមានវណ្ឌពណ៌មាស ។ សញ្ញាសំគាល់នគរបាលដាក់មុខមួករបស់នាយនគរបាលថ្នាក់ឧត្ដមសេនីយ វរៈសេនីយ មានក្បាច់ជ័យជំនះរួចពីក្រោមរាងជាស្លែងក្របី ។

មាត្រា ៤ .— សញ្ញាបានន្ទរស័ក្ដិនាយនគរបាលជារូបផ្កាយនៅពីលើចាំនស្មា ផ្ទៃពណ៌បៃតងដែលមានខ្សែមួយបិទភ្ជាប់ផ្នែកខាងចុង និងមានរឹមជុំវិញពណ៌ក្រហមពាក់នៅលើស្មាអាវទាំង សងខាង ។

- អនុសេនីយត្រី វរៈសេនីយត្រី ឧត្ដមសេនីយត្រី : ផ្កាយមួយ
- អនុសេនីយទោ វរៈសេនីយទោ ឧត្ដមសេនីយទោ : ផ្កាយពីរ
- អនុសេនីយឯកបំរុង : ផ្កាយបី " ផ្កាយធំពីរ តូចមួយ "
- អនុសេនីយឯក វរៈសេនីយឯក ឧត្ដមសេនីយឯក : ផ្កាយបី

មាត្រា ៥ .— រូបផ្កាយរបស់នាយនគរបាលថ្នាក់ឧត្ដមសេនីយ មានពណ៌ទឹកមាស ទំហំធំជាងរូបផ្កាយរបស់នាយនគរបាលថ្នាក់វរៈសេនីយរៀបរៀងជាបណ្ដោយ ។

រូបផ្កាយរបស់នាយនគរបាលថ្នាក់វរៈសេនីយមានពណ៌ទឹកមាស ទំហំធំជាងរូបផ្កាយរបស់នាយនគរបាលថ្នាក់អនុសេនីយ រៀបរៀងជាបណ្ដោយ ។

រូបផ្កាយរបស់នាយនគរបាលថ្នាក់អនុសេនីយ ពណ៌ទឹកប្រាក់មានទំហំតូចជាងរូបផ្កាយរបស់នាយនគរបាលថ្នាក់វរៈសេនីយ ។ រូបផ្កាយថ្នាក់អនុសេនីយត្រី រៀបចំកណ្ដាល លើឆ្នូតបណ្ដោយ

ពណ៌ទឹកមាស ។ រូបផ្កាយអនុសេនីយទោ រៀបជាទទឹង ។ រូបផ្កាយថ្នាក់អនុសេនីយឯក-អនុសេនីយឯកចំរុង រៀបរៀងជារាងត្រីកោណ ។

មាត្រា ៦ .— សញ្ញាឋានន្តរសក្តិរបស់នាយនគរបាលថ្នាក់ឧត្តមសេនីយ មានខ្សែពណ៌ទឹកមាសរាងមូលដែលមានរូបប្រាសាទកំពូលប្រាំនៅចំកណ្តាល អមសងខាងដោយកំរងកួរស្រូវពណ៌ទឹកមាស និងមានវ័ណ្ឌមួយព័ទ្ធជុំវិញរលេចដោយក្បាច់ភ្ញីទេសពណ៌ទឹកមាសនៃបរិមណ្ឌលក្រហម ។

មាត្រា ៧ .— សញ្ញាឋានន្តរសក្តិរបស់នាយនគរបាលថ្នាក់វរៈសេនីយ មានខ្សែពណ៌ទឹកមាសរូបដូចខ្សែរបស់នាយនគរបាលថ្នាក់ឧត្តមសេនីយ និងមានឆ្នូតពីរពណ៌ទឹកមាសក្បាញបណ្តែតក្បាច់ចិញ្ចាចស្របតាមបណ្តោយតែមសងខាងផ្តៃសក្តិ ។

មាត្រា ៨ .— សញ្ញាឋានន្តរសក្តិរបស់នាយនគរបាលថ្នាក់អនុសេនីយ មានខ្សែពណ៌ទឹកប្រាក់រូបដូចខ្សែរបស់នាយនគរបាលថ្នាក់វរៈសេនីយ និងមានឆ្នូតពណ៌ទឹកមាសមួយក្បាញបណ្តែតក្បាច់ចិញ្ចាចចំកណ្តាលតាមបណ្តោយផ្ទៃសក្តិ ។

មាត្រា ៩ .— សញ្ញាឋានន្តរសក្តិរបស់នាយនគរបាលរង ពលនគរបាល មានខ្សែពណ៌ទឹកប្រាក់ នៅខាងចុងប៉ាន់ស្មា ដែលមានផ្ទៃពណ៌បៃតង និងមែនពណ៌ក្រហមដូចសញ្ញាឋានន្តរសក្តិរបស់នាយនគរបាលថ្នាក់អនុសេនីយ ។

ក- សញ្ញាឋានន្តរសក្តិរបស់នាយនគរបាលរង មានឆ្នូតរាងមុំទាលពណ៌លឿងនៅដើមនៃប៉ាន់ស្មា :-

១- ពលបាលត្រី : ឆ្នូតមុំទាល ១

២- ពលបាលទោ : ឆ្នូតមុំទាល ២

៣- ពលបាលឯក : ឆ្នូតមុំទាល ៣ រៀបរៀងជាលំដាប់លំដោយពីដើមទៅចុង

ខ- សញ្ញាឋានន្តរសក្តិរបស់ពលនគរបាល :-

១- ពលទោ : ផ្ទៃប៉ាន់ស្មាពណ៌បៃតងលាត

២- ពលឯក : មានឆ្នូតពណ៌លឿងចំកណ្តាលតាមបណ្តោយនៃប៉ាន់ស្មា

មាត្រា ១០ .— សញ្ញាពាក់នៅលើចុងកអាវ ទាំងសងខាងរបស់នាយនគរបាល នាយនគរបាលរង ពលនគរបាលមានផ្ទៃពណ៌បៃតង និងរឹមជុំវិញពណ៌ក្រហម ហើយត្រូវបានពាក់នៅពេលពាក់សក្តិនៅលើស្មា ។

ក- សញ្ញាកអាវរបស់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ មានវណ្ណមួយពីទូជាប់ជ្រុងគែមរិម ក្របាមមានរំលេចក្បាច់ភ្ញីមេសពណ៌ទឹកមាស និងមានក្បាច់ផ្កាស្រូវទ្វេគ្រាប់ពណ៌ទឹកមាសនៅចំណែកចំកណ្តាល តាមបណ្តោយសញ្ញាកអាវផ្តែសក្តិ ។

ខ- សញ្ញាកអាវរបស់នាយនគរបាលថ្នាក់វរៈសេនីយ៍ មានវណ្ណមួយពីទូជាប់ជ្រុង រំលេចដោយក្បាច់ធ្មេញក្រពើ ពណ៌ទឹកមាស គែបរិមក្របាម និងមានសញ្ញានគរបាលមួយផុសចំកណ្តាលសញ្ញាកអាវលើផ្តែសក្តិ ។

គ- សញ្ញាកអាវរបស់នាយនគរបាលថ្នាក់អនុសេនីយ៍ ដូចសញ្ញាកអាវរបស់នាយនគរបាលថ្នាក់វរៈសេនីយ៍ ចុំន្តែវណ្ណក្បាច់ធ្មេញក្រពើពណ៌ទឹកប្រាក់ ។

ឃ- សញ្ញាកអាវរបស់នាយនគរបាលរង ពលនគរបាល មានសញ្ញានគរបាលមួយផុសចំកណ្តាលដូចថ្នាក់អនុសេនីយ៍

មាត្រា ១១.- សញ្ញាបានន្តរសក្តិពាក់លើចុងកអាវ ប្រើប្រាស់នៅពេលមិនពាក់បានន្តរសក្តិលើស្មា មានរាងដូចសញ្ញាកអាវដែរ និងមានសញ្ញានគរបាលមួយនៅចំកណ្តាលនៃផ្នែកខាងលើ ។

ក- សញ្ញាបានន្តរសក្តិ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ មានរូបផ្កាយ និងសញ្ញានគរបាលពណ៌ទឹកមាស :

- ឧត្តមសេនីយ៍ឯក : ផ្កាយបី
- ឧត្តមសេនីយ៍ទោ : ផ្កាយពីរ
- ឧត្តមសេនីយ៍ត្រី : ផ្កាយមួយ

ខ- សញ្ញាបានន្តរសក្តិ នាយនគរបាលថ្នាក់វរៈសេនីយ៍ មានរូបផ្កាយ និងសញ្ញានគរបាលពណ៌ទឹកមាស :

- វរៈសេនីយ៍ឯក : ផ្កាយបី
- វរៈសេនីយ៍ទោ : ផ្កាយពីរ
- វរៈសេនីយ៍ត្រី : ផ្កាយមួយ

គ- សញ្ញាបានន្តរសក្តិ នាយនគរបាលថ្នាក់អនុសេនីយ៍ មានសញ្ញានគរបាលពណ៌ទឹកមាសរូបផ្កាយពណ៌ទឹកប្រាក់ :

- អនុសេនីយ៍ឯក : ផ្កាយបី

- អនុសេនីយឯកបំរុង : ផ្កាយបី « ធំពីរ តូចមួយ »
- អនុសេនីយទោ : ផ្កាយពីរ
- អនុសេនីយត្រី : ផ្កាយមួយ

ឃ- សញ្ញាឋានន្តរសក្តិ នាយនគរបាលរង មានសញ្ញានគរបាលពណ៌ទឹកមាស និងមានឆ្នូតរាងមុំទាលពណ៌លឿង :

- ពលបាលឯក : ឆ្នូតមុំទាលបី
- ពលបាលទោ : ឆ្នូតមុំទាលពីរ
- ពលបាលត្រី : ឆ្នូតមុំទាលមួយ

ង- សញ្ញាឋានន្តរសក្តិ ពលនគរបាល មានសញ្ញានគរបាលពណ៌ទឹកមាស :

- ពលឯក : មានឆ្នូតពណ៌លឿងពុះចំកណ្តាលតាមបណ្តោយផ្លែសក្តិចុងកអាវ
- ពលទោ : មានផ្លែពណ៌បៃតងលាត

មាត្រា ១២.- សញ្ញាសំគាល់ប្រភេទ កងកម្លាំងនគរបាលកំណត់ដូចខាងក្រោម :

- សញ្ញាសំគាល់កងកម្លាំងពេទ្យនគរបាល មានរូបកាកបាទក្រហមនៅចំកណ្តាលផ្លែពណ៌ស និង មានគំរងគួរស្រូវអមសងខាងពណ៌ទឹកមាស ។

- សញ្ញាសំគាល់កងកម្លាំង កម្មករបច្ចេកទេសនគរបាល មានរូបញញួរ និង ម៉ាឡេតខ្វែងគ្នា នៅចំកណ្តាលផ្លែ ពណ៌ក្រហម និងមានគំរងគួរស្រូវអមសងខាងពណ៌ទឹកមាស ។

- សញ្ញាសំគាល់កងកម្លាំងកម្មករបើកបរ និង គ្រូតចរាចរមានរូបចង្កូតរថយន្តនៅចំកណ្តាលផ្លែពណ៌ក្រហម និង មានគំរងគួរស្រូវអមសងខាង ពណ៌ទឹកមាស ។

- សញ្ញាសំគាល់កងកម្លាំងនគរបាលអគ្គិភ័យ មានរូបរថយន្តអគ្គិភ័យនៅចំកណ្តាលផ្លែពណ៌ក្រហម និងមានគំរងគួរស្រូវអមសងខាងពណ៌ទឹកមាស ។

- សញ្ញាសំគាល់កងកម្លាំងនគរបាល សិល្បៈដូរ្យតន្ត្រីមានរូបពិននៅចំណ្តាលផ្លែពណ៌ក្រហម និងមានគំរងគួរស្រូវអមសងខាងពណ៌ទឹកមាស ។

- សញ្ញាសំគាល់កងកម្លាំងនគរបាលសន្តិសុខព្រំដែន មានរូបខែល និងដាវខ្វែងគ្នានៅចំកណ្តាលផ្លែពណ៌ក្រហម និងមានគំរងគួរស្រូវអមសងខាងពណ៌ទឹកមាស ។

- សញ្ញសំគាល់ខាងលើ សំរាប់ដាក់លើសញ្ញាកអាវ ឬ សញ្ញាឋានន្តរសក្តិពាក់នៅខាងចុងកអាវ របស់នាយនគរបាល នាយនគរបាលរង ពលនគរបាល កម្មករបច្ចេកទេស កម្មករបើកបរ គ្រូតចរាចរ សិល្បៈតន្ត្រី អគ្គិភ័យ ពេទ្យ និងសន្តិសុខព្រំដែន នៃកងកម្លាំងនគរបាលប្រជាជន ។

មាត្រា១៣ .— នគរបាលប្រជាជនគ្រប់ប្រភេទត្រូវពាក់អក្សរសំគាល់អង្គភាព និងអត្តលេខសំគាល់ខ្លួនដែលកំណត់ដោយក្រសួងមហាផ្ទៃ ។

មាត្រា១៤ .— ឯកសណ្ឋានថ្ងៃបុណ្យរបស់នាយនគរបាលថ្នាក់ ឧត្តមសេនីយ ៖

- មួកកេបពីពណ៌ដូចអាវ ជើងនឹងវណ្ណមួកពណ៌ក្រហម និងមានខ្សែសយពីរក្បាច់ផ្កាម្លូងពណ៌ទឹកមាសចងភ្ជាប់ទន្ទឹមគ្នា ។ សញ្ញានគរបាលដាក់មុខមួកត្រូវភ្ជាប់នៅផ្នែកខាងលើខ្សែសយពីរ ។ នៅលើគែមក្បាំងមួកមានរូបក្បាច់ផ្កាម្លូងពីរជួរពណ៌ទឹកមាស ។

– សំលៀកបំពាក់ក្រៅ អាវពណ៌ស្លឹកចេកចាស់ បើកករហូតដល់ឡេវទីបី រាប់ពីក្រោមឡើងលើ ជាយកអាវ ចុងដៃអាវចំក្រណាត់ពណ៌ក្រហម និងមានខ្សែជ័យជំនះពីរពាក់ឆៀងលើស្មា " ចុងសក្តិ " ចុះដល់ខ្សែក្រវ៉ាត់ក្រៅខាងឆ្វេងដៃ ។

- នៅតាមបណ្តោយថ្នេរខោខាងក្រៅទាំងសងខាងមានឆ្នូតមួយ ពណ៌ក្រហម ។
- អាវក្នុងដៃវែងកខុបពណ៌ដូចអាវធំ ។
- ក្រវ៉ាត់កពណ៌ខៀវចាស់ ។
- ស្រោមដៃពណ៌ស ស្រោមជើងពណ៌ដូចខោ ។
- ស្បែកជើងកខ្វិពណ៌ខ្មៅ ។

មាត្រា១៥ .- ឯកសណ្ឋានថ្ងៃបុណ្យរបស់នាយនគរបាលថ្នាក់វរៈសេនីយ ដូចឯកសណ្ឋានរបស់នាយនគរបាលថ្នាក់ឧត្តមសេនីយ ប៉ុន្តែនៅគែមក្បាំងមួកគ្មានរូបក្បាច់ផ្កាម្លូង ជើង និងវណ្ណមួកពណ៌បៃតង ចុងដៃអាវ ជាយកអាវ ចំក្រណាត់ពណ៌បៃតងហើយគ្មានខ្សែជ័យជំនះ។

— នៅតាមបណ្តោយថ្នេរខាងក្រៅទាំងសងខាង មានឆ្នូតមួយពណ៌បៃតង ។

មាត្រា១៦ .- ឯកសណ្ឋានថ្ងៃបុណ្យរបស់នាយនគរបាល ថ្នាក់អនុសេនីយ ដូចឯកសណ្ឋានរបស់នាយនគរបាលថ្នាក់ វរៈសេនីយ ប៉ុន្តែជើង និងវណ្ណមួកពណ៌ខៀវចាស់ ខ្សែសយសំប៉ែតពណ៌ទឹកមាស អាវខាងក្នុងពណ៌ដូចអាវធំ

មាត្រា១៧.- សំលៀកបំពាក់របស់កម្មាភិបាល យុទ្ធជន និងឯកសណ្ឋានថ្ងៃបុណ្យរបស់នាយនគរបាលរង ពលនគរបាលចំណុះបណ្តាអង្គភាព ដែលបំពេញភារកិច្ចជាកិត្តិយស ហែហម ព្យុហយាត្រា សិល្បៈអាស្រ័យដោយក្រសួងមហាផ្ទៃកំណត់ ។

មាត្រា១៨ .- សញ្ញាសំគាល់នគរបាល សញ្ញាឋានន្តរសក្តិ សញ្ញាកអាវ និងសញ្ញាសំគាល់ប្រភេទកងកម្លាំងនគរបាលត្រូវបានផ្តល់អោយនាយនគរបាល នាយនគរបាលរង ពលនគរបាល នៅក្នុងជួរ ដើម្បីបំពេញភារកិច្ច ហើយប្រើប្រាស់ត្រឹមត្រូវតាមការកំណត់ក្នុងអនុក្រឹត្យនេះ ។

មាត្រា១៩ .- ឯកសណ្ឋានថ្ងៃបុណ្យ ផ្តល់អោយនាយនគរបាល ក្រៅពីបេបសំលៀកបំពាក់ប្រចាំឆ្នាំ ទុកសំរាប់ប្រើប្រាស់ក្នុងថ្ងៃបុណ្យ អង្គមិទ្ទិញ ព្យុហយាត្រា សម្តែងកម្លាំង និងថ្ងៃបុណ្យខួបអនុស្សាវរីយ៍ ទទួល និងបំពាក់ឥស្សរិយយសទទួលភ្ញៀវក្នុង និងក្រៅប្រទេសតាមរូបភាពកិត្តិយស ។

មាត្រា២០ .- នាយនគរបាលប្រជាជន ពេលផ្ទេរទៅស្ថាប័នផ្សេង ។ ឬចូលរបបចូលនិវត្តន៍ មានគ្រប់រយៈពេលម្ភៃឆ្នាំ ប្រតិបត្តិការក្នុងកងកម្លាំងនគរបាល លើកលែងតែថ្នាក់ឧត្តមសេនីយ និង បណ្ណាសមមិត្តរដ្ឋមន្ត្រី អនុរដ្ឋមន្ត្រី គ្មានកំណត់រយៈពេលត្រូវបានយកតាមសញ្ញានគរបាលឋានន្តរសក្តិ សញ្ញាឯកសណ្ឋានថ្ងៃបុណ្យដើម្បីទុកជាអនុស្សាវរីយ៍ និង បានប្រើប្រាស់ដូចមានចែងក្នុងមាត្រា ១៨ ។

មាត្រា២១ .- ការផលិតសំភារៈសក្តិ ការលក់ ស្តុក ឬចែកចាយប្រើប្រាស់សំលៀកបំពាក់ប្រភេទសាច់ក្រណាត់ពណ៌ស្លឹកចេកចាស់ ឬស្លឹកចេកខ្ចី របស់កងកម្លាំងនគរបាលប្រជាជន ដោយគ្មានការអនុញ្ញាតពីក្រសួងមហាផ្ទៃ ត្រូវហាមឃាត់ ។

ជនណាដែលក្លែងបន្លំប្រើប្រាស់សំភារៈសក្តិ សំលៀកបំពាក់របស់កងកម្លាំងនគរបាលប្រជាជន ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

នគរបាលណាដែលអនុវត្តខុស ពីការកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវវិនិច្ឆ័យដាក់វិន័យរដ្ឋបាលតាមបទបញ្ជាផ្ទៃក្នុងរបស់កងកម្លាំងនគរបាលប្រជាជន ឬតាមច្បាប់ជាធរមាន ។

មាត្រា២២ .- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវកំណត់ដាក់ស្តែងដើម្បីអនុវត្តអនុក្រឹត្យនេះ ។

មាត្រា២៣ .- បទបញ្ញត្តិណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា២៤ .- ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងពាក់ព័ន្ធ និងគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង ៗ ខ្លួន ។

មាត្រា២៨ - អនុក្រឹត្យនេះ មានអានុភាពគតិយុត្តិចាប់តាំងពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធាន

ហត្ថលេខា និង ត្រា

ហ៊ុន សែន

ភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩០

អនុក្រឹត្យលេខ ០៥ អនក្រ

ស្តីពីភារកិច្ច និងផលប្រយោជន៍របស់នគរបាលប្រជាជន

ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីអំពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣៩ ក្រ.ច ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋ ស្តីពីការកែប្រែអង្គការចាត់តាំង តួនាទី និងភារកិច្ចរបស់ទីស្តីការ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- បានឃើញក្រឹត្យ-ច្បាប់លេខ ៤០ ក្រ.ច ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋ ស្តីពីឋានន្តរសក្តិ របស់នគរបាលប្រជាជន
- បានឃើញក្រឹត្យ-ច្បាប់លេខ ០៧ ក្រ.ច ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៨៣ ស្តីពីសមត្ថកិច្ច និងនីតិវិធី នៃការធ្វើច្បាប់ និងបទបញ្ញា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា១ - កម្មាភិបាល យុទ្ធជនកំពុងបំពេញការងារក្នុងកងកម្លាំងនគរបាលប្រជាជន ត្រូវចាត់ទុកដូចជាកំពុងបំពេញភារកិច្ចយោធាក្នុងជួរកងកម្លាំងប្រដាប់អាវុធប្រជាជនកម្ពុជា ។

មាត្រា ២ .- កម្មាភិបាល យុទ្ធជន នគរបាលមានភារកិច្ច :

- ផ្តាច់ខាតស្មោះត្រង់ចំពោះមាតុភូមិ ចំពោះបក្សប្រជាជនបដិវត្ត ចំពោះរដ្ឋកម្ពុជា និងប្រជាជនកម្ពុជា ។
- អនុវត្តម៉ឺងម៉ាត់រាល់គោលការណ៍ គោលនយោបាយរបស់បក្ស ច្បាប់របស់រដ្ឋ លក្ខន្តិកៈ សកម្មភាព និងបទបញ្ជាផ្ទៃក្នុង របស់កងកម្លាំងនគរបាលប្រជាជន ។
- គោរពសិទ្ធិ សេរីភាព ប្រជាធិបតេយ្យរបស់ប្រជាជន និងបំរើប្រជាជនអស់មួយជីវិត ។
- មានអង្គការចាត់តាំង និងវិន័យម៉ឺងម៉ាត់ លើកកំពស់ស្មារតីប្រុងប្រយ័ត្នបដិវត្ត ចរិតស្មោះសរ សុភាពរាបសារ ស្រឡាញ់មុខជំនាញឯកទេស រក្សាការសម្ងាត់ ត្រៀមប្រយុទ្ធ និងប្រយុទ្ធយ៉ាងអង់អាចក្លាហានចំពោះខ្មាំងសត្រូវ គោរពស្រឡាញ់ រាប់អានប្រជាជន ។
- កម្មាភិបាល យុទ្ធជន នគរបាលទោះបីស្ថិតនៅមុខដំណែង ឬឋានន្តរស័ក្តិណាក៏ដោយ ក៏សុទ្ធតែមានគោលដៅ និងឧត្តមគតិតែមួយ ស្ម័គ្រលះជីវិតដើម្បីការពារបក្សប្រជាជនបដិវត្តកម្ពុជា រដ្ឋ និង ប្រជាជនកម្ពុជា ។
- កម្មាភិបាលថ្នាក់លើ ត្រូវធ្វើគំរូគោរពស្រឡាញ់ ហើយត្រូវយកចិត្តទុកដាក់ដល់កម្មាភិបាល យុទ្ធជននគរបាលថ្នាក់ក្រោម ។ កម្មាភិបាល និង យុទ្ធជននគរបាលថ្នាក់ក្រោមត្រូវគោរព និងប្រតិបត្តិតាមបទបញ្ជារបស់ថ្នាក់លើ ។

មាត្រា ៣ .- កម្មាភិបាល យុទ្ធជន កំពុងបំរើការងារក្នុងជួរកងកម្លាំងនគរបាលប្រជាជន ត្រូវបានទទួលបៀវត្សតាមមុខដំណែង និងថ្នាក់នៃឋានន្តរស័ក្តិ ឧបត្ថម្ភអតីតភាព ក្នុងកងកម្លាំងប្រដាប់អាវុធ ឧបត្ថម្ភសមរភូមិមុខនិងតាមតំបន់ ឧបត្ថម្ភរបួសកម្មទទួលរបបយុទ្ធជនពលី ពិការមរណៈ សំរាកច្បាប់ សំរាកលំហែកាយ សំរាកដោយបាត់បង់សមត្ថភាពពលកម្ម ផ្ទេរទៅស្ថាប័នផ្សេងចេញពីជួរ សំរាកបន្ថែមនៅពេលសំរេចឆ្នើមភារកិច្ច ត្រូវបានទទួលអាទិភាពផ្តល់ប្រាក់ឧបត្ថម្ភពេលជួបលំបាក តែមប្រៃសណីយ៍ និងទទួលបណ្តារបបផ្សេងៗទៀតដែលរដ្ឋបានកំណត់ ។ ក្នុងពេលចុះបំពេញភារកិច្ចត្រូវបានអាទិភាពក្នុងការធ្វើដំណើរទៅមកតាមមធ្យោបាយគមនាគមន៍សាធារណៈក្នុងករណីបន្ទាន់មានសិទ្ធិប្រើប្រាស់មធ្យោបាយគមនាគមន៍ ទូរទាក់ទង និងមធ្យោបាយបច្ចេកទេសផ្សេងទៀតរបស់អង្គការ រដ្ឋ អង្គការសង្គម និងរបស់ឯកជន ព្រមទាំងអ្នកដែលកំពុងបញ្ជាប្រើប្រាស់មធ្យោបាយទាំងនោះ « លើកលែងតែមធ្យោបាយរបស់គណៈប្រតិភូ និង អគ្គទូត » ។

មាត្រា ៤ .— កម្មាភិបាល បុគ្គលិក កម្មករ ដែលមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីចូលនិវត្តន៍ ហើយ ប៉ុន្តែដោយសារការចាំបាច់របស់ក្រសួង និង ដោយសុខភាពរបស់សាមីខ្លួនអាចធានាការងារបានផង ដោយសាមីខ្លួនយល់ព្រមផង ក្រសួងគ្រប់គ្រងអាចសំរេច ឬ ស្នើសុំទៅស្ថាប័ន មានសមត្ថកិច្ចអោយបន្តការងារមួយរយៈពេលទៀត ។ ក្នុងករណីនេះគេនៅមានសិទ្ធិពេញលេញដូចកម្មាភិបាល បុគ្គលិក កម្មករដដែល ។

ចំពោះថេរវេលាអោយបន្តការងារ ត្រូវកំណត់អោយបានសមស្របទៅតាមស្ថានភាពរបស់សាមីខ្លួន ។

កម្មាភិបាល បុគ្គលិក យុទ្ធជន ដែលប្រយុទ្ធនៅសមរភូមិ ដោយត្រូវរបួស ពិការ បើសិនជាលក្ខណៈនៃភាពពិការ និងសុខភាពរបស់សាមីខ្លួនអាចធានាបន្តការងារបាន អង្គភាពគ្រប់គ្រងត្រូវពិនិត្យជ្រើសរើសបុគ្គលនោះ ដើម្បីប្រគល់ការងារសមស្របទៅតាមសមត្ថភាពជាក់ស្តែង ក្នុងករណីនេះ គេក៏នៅមានសិទ្ធិពេញលេញដូចកម្មាភិបាល បុគ្គលិក កម្មករ ដទៃ ។

មាត្រា ៥ .— អង្គភាពនគរបាល និង បុគ្គលដែលមានស្នាដៃក្នុងការប្រយុទ្ធ និង កិច្ចប្រតិបត្តិការមានរយៈពេលពលីកម្ម ក្នុងជួរកងកំលាំងនគរបាលប្រជាជន ផ្អែកតាមស្នាដៃនិងរយៈពេលពលីកម្ម ត្រូវបានពិនិត្យសរសើរជូនរង្វាន់ គ្រឿងឥស្សរិយយស កិត្តិនាម និងរូបភាពសរសើរជូនរង្វាន់ផ្សេងៗ ទៀតរបស់រដ្ឋ ។

មាត្រា ៦ .— គ្រួសារកម្មាភិបាល យុទ្ធជននគរបាលប្រជាជន ត្រូវបានទទួលរបបគោលនយោបាយសមរភូមិក្រោយ ។ គណៈកម្មាធិការប្រជាជន និងអង្គការមហាជនតាមមូលដ្ឋានមានភារកិច្ចជួយឧបត្ថម្ភទាំងស្មារតី សម្ភារៈ និង អនុវត្តរាល់របបដែលរដ្ឋកំណត់ ។

មាត្រា ៧ .— កម្មាភិបាល យុទ្ធជនណាដែលបំពារបំពានច្បាប់របស់រដ្ឋ លក្ខន្តិកៈ សកម្មភាព បទបញ្ជាផ្ទៃក្នុង និង របបប្រតិបត្តិការ របស់កងកំលាំងនគរបាលប្រជាជន គឺ ត្រូវដាក់វិន័យ ឬ ផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

មាត្រា ៨ .— ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងពាក់ព័ន្ធ និងគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៤ —. អនុក្រឹត្យនេះ មានអានុភាពគតិយុត្ត ចាប់តាំងពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី
ប្រធាន
ហត្ថលេខា និង ត្រា
ហ៊ុន សែន

ភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩០

អនុក្រឹត្យលេខ ០៨ អនក្រ
ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានទេសចរណ៍
ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

- បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ. ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ១៩៨២

- បានឃើញក្រឹត្យ-ច្បាប់លេខ ៣៧ ក្រ. ច ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ ១៩៨៨ ស្តីពីការបង្កើតអគ្គនាយកដ្ឋានទេសចរណ៍

- បានឃើញក្រឹត្យ-ច្បាប់លេខ ០៧ ក្រ.ច ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ១៩៨២ ស្តីពីសមត្ថកិច្ច និង នីតិវិធីនៃការធ្វើច្បាប់ និង បទបញ្ញា

- តាមសំណើរបស់អគ្គនាយក ទេសចរណ៍

សំរេច

មាត្រា .— អគ្គនាយកដ្ឋានទេសចរណ៍ជាស្ថាប័នស្ថិតក្រោមឱវាទក្រុមប្រឹក្សារដ្ឋមន្ត្រីមាន មុខនាទីជួយក្រុមប្រឹក្សារដ្ឋមន្ត្រី ក្នុងការគ្រប់គ្រងវិស័យទេសចរណ៍ នៅក្នុងរដ្ឋកម្ពុជា។

មាត្រា ២ .— អគ្គនាយកដ្ឋានទេសចរណ៍ មានភារកិច្ច និងសិទ្ធិដូចខាងក្រោម :

១. រៀបចំគំរោងការងារសេវាកម្មបំរើវិស័យទេសចរណ៍អោយបានគតាពទូទាំងប្រទេស ។

២- គ្រប់គ្រងអាជីវកម្ម សណ្ឋាគារ ផ្ទះភ្ញៀវ ភោជនីយដ្ឋាន រង្គសាលសំរាប់ទេសចរណ៍

ទីភ្នាក់ងារទេសចរណ៍ក្នុងប្រទេស និង តំណាងទីភ្នាក់ងារបរទេសបំរើវិស័យទេសចរណ៍ ជួលរថយន្តសំរាប់ទេសចរណ៍ លក់វត្ថុអនុស្សាវរីយ៍សំរាប់ទេសចរណ៍ ។

៣. គ្រប់គ្រងថ្លៃដឹកជញ្ជូនទេសចរណ៍ទស្សនាតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស គ្រប់គ្រងថ្លៃស្នាក់នៅ ម្ហូបអាហារផ្សេង ៗ គ្រប់គ្រងថ្លៃលក់ និងគុណភាពផលិតផលសិល្បៈ និងវត្ថុអនុស្សាវរីយ៍សំរាប់ទេសចរណ៍ ។

៤. គ្រប់គ្រងក្រុមហ៊ុនទេសចរណ៍នៅខេត្ត-ក្រុង ទាំងខាងការងារចាត់តាំង កម្មាភិបាល ដោយមានការឯកភាពពីមូលដ្ឋាន ទាំងខាងបច្ចេកទេស និង នយោបាយទេសចរណ៍ ។

៥. គ្រប់គ្រងការរៀបចំការសាងសង់ ការជួសជុល និង ការកែលំអរមណីយដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន រង្គសាលសំរាប់ទេសចរណ៍ទូទាំងប្រទេស

៦. ឃោសនាផ្សព្វផ្សាយពាណិជ្ជកម្មទេសចរណ៍នៅក្នុង និង ក្រៅប្រទេស ។

៧. បណ្តុះបណ្តាលខាងវិជ្ជាជីវៈ ផ្នែកទេសចរណ៍សណ្ឋាគារ និង ភោជនីយដ្ឋានសំរាប់បំរើវិស័យទេសចរណ៍ក្នុង និង ក្រៅប្រទេស ។

៨. ធ្វើទំនាក់ទំនង និង ចុះហត្ថលេខាជាមួយក្រុមហ៊ុនបរទេស លើវិស័យទេសចរណ៍ ។

មាត្រា ៣ .— រចនាសម្ព័ន្ធចាត់តាំងរបស់អគ្គនាយកដ្ឋានទេសចរណ៍រួមមាន :

១. មន្ទីរ

២. នាយកដ្ឋានបច្ចេកទេស

៣. នាយកដ្ឋានទេសចរណ៍

៤. នាយកដ្ឋានគ្រប់គ្រងសណ្ឋាគារ ភោជនីយដ្ឋាន

មាត្រា ៤ .— អគ្គនាយកដ្ឋានទេសចរណ៍ មានអគ្គនាយកមួយរូប និងអគ្គនាយករងមួយចំនួនជាជំនួយការ ។

មាត្រា ៥ .— បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ .— ខុទ្ទកាល័យគណៈប្រឹក្សារដ្ឋមន្ត្រី អគ្គនាយកដ្ឋានទេសចរណ៍ ក្រសួងស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង ៗ ខ្លួន ។

មាត្រា ៧ ៖ អនុក្រឹត្យនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃដែលប្រកាសផ្សាយជាសាធារណៈ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធាន៖

ហត្ថលេខា និងត្រា

ហ៊ុន សែន

២ - សេចក្ដីសំរេច

ភ្នំពេញ ថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩០

សេចក្ដីសំរេច លេខ ២៧ សសរ

ស្ដីពីការបំពេញបន្ថែមខ្លឹមសារមួយចំនួន
នៃសេចក្ដីសំរេចលេខ ១៧ សសរ ចុះថ្ងៃទី ៣០-០១-៩០
របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

ក្រុមប្រឹក្សារដ្ឋមន្ត្រី

— បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

— បានឃើញច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញសេចក្ដីសំរេចលេខ ១៧ សសរ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩០ ស្ដីពីការបង្កើតគណៈកម្មការត្រួតពិនិត្យការគ្រប់គ្រងសាច់ប្រាក់របស់មូលដ្ឋានខេត្ត - ក្រុងរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

— ពិនិត្យសភាពការណ៍ជាក់ស្ដែង

សំរេច

ប្រការ ១ : ត្រូវបានបំពេញបន្ថែមខ្លឹមសារមួយចំនួនចូលទៅក្នុងខ្លឹមសារដែលមានចែងក្នុងប្រការ ២ វាក្យខ័ណ្ឌទី ១ នៃសេចក្ដីសំរេចលេខ១៧ សសរ ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ ១៩៩០ ដូចខាងក្រោម :

— គណៈកម្មការនេះ មានភារកិច្ចចុះក្រសួងការបរទេស ក្រសួងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ នាយកដ្ឋានផែនការ និងហិរញ្ញកិច្ច ធនាគារជាតិ ធនាគារពាណិជ្ជកម្មក្រៅប្រទេស និងខេត្ត - ក្រុងសំខាន់ៗដើម្បី :

ប្រការ ២ : រាល់ខ្លឹមសារដែលមានចែងក្នុងប្រការផ្សេងទៀត នៃសេចក្ដីសំរេចលេខ ១៧ សសរ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩០ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៅរក្សាទុកជាធរមានដដែល ។

ប្រការ ៣ ៖ ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងហិរញ្ញវត្ថុ ក្រសួងត្រួតពិនិត្យ ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម ក្រសួងការពារប្រទេស ក្រសួងមហាផ្ទៃ ធនាគារជាតិនៃប្រជាជនកម្ពុជា និងគណៈកម្មាធិការប្រជាជនខេត្ត - ក្រុង ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី
ប្រធាន
ហត្ថលេខា និង ត្រា
ហ៊ុន សែន

ភ្នំពេញ , ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩០

សេចក្តីសំរេច លេខ ២៨ ស.ស.រ
ស្តីពី តំរិតកំណត់ផែនការចំណូល-ចំណាយរូបិយប័ណ្ណខ្លាំង
សំរាប់ឆ្នាំ ១៩៩០

ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២
- តាមស្មារតីអង្គប្រជុំគណអចិន្ត្រៃយ៍ ក្រុមប្រឹក្សារដ្ឋមន្ត្រី នាថ្ងៃទី៨ ខែធ្នូ ឆ្នាំ ១៩៨៩
- តាមសំណើរបស់សមមិត្តរដ្ឋមន្ត្រី ក្រសួងផែនការ

សំរេច

ប្រការ ១ : ប្រគល់តំរិតកំណត់ផែនការចំណូល-ចំណាយរូបិយប័ណ្ណខ្លាំងសំរាប់ ឆ្នាំ១៩៩០ ជូនបណ្តាក្រសួង ស្ថាប័ន និងអង្គភាពនានា ដូចមានតារាងជូនភ្ជាប់ជាមួយស្រាប់ ។

ប្រការ ២ : ក្រោយពីបានទទួលតំរិតកំណត់ផែនការ , ចំណូលរូបិយប័ណ្ណខ្លាំងសំរាប់ឆ្នាំ១៩៩០ ដែលមានចំនួនទឹកប្រាក់សរុប ៤០.៣៦២.០០០ ដុល្លារ យូអេស "សែសិបលានបីរយហុកសិបពីរពាន់ " ក្នុងនោះ :

- ចំណូលក្នុងពាណិជ្ជកម្ម : ២៩.៨០៤.០០០ ដុល្លារអ៊ិយអេស
- ចំណូលក្រៅពាណិជ្ជកម្ម : ៨.៦៩៦.០០០ ដុល្លារអ៊ិយអេស
- ទុនអាជីវកម្មធនាគារជាតិ : ៧.៥០០.០០០ ដុល្លារអ៊ិយអេស

គ្រប់ក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធ ត្រូវរិះរកគ្រប់វិធានការបង្កើន ចំណូលរូបិយប័ណ្ណ តាមគ្រប់ប្រភព ទាំងយុទ្ធវិធី ទាំងការចាត់តាំងអនុវត្ត ។

ប្រការ ៣ : ក្រោយពីទទួលកំរិតកំណត់ផែនការចំណាយរូបិយប័ណ្ណ សំរាប់ ឆ្នាំ ១៩៩០ ដែលមានទឹកប្រាក់សរុបចំនួន ៤៦.០០០.០០០ ដុល្លារអ៊ិយអេស « សែសិបប្រាំមួយលាន » ក្នុងនោះ ៖

- ចំណាយដោយទុនថវិការដ្ឋផ្តល់ ២៣.០៦៧.៤១៤ ដុល្លារអ៊ិយអេស
- ចំណាយដោយទុនរបស់អង្គភាព ១៥.៩៤៧.២៤៥ ដុល្លារអ៊ិយអេស

ក្នុងប្រភពចំណាយទាំងពីរនេះ ចែកចេញជា :

- ចំណាយក្នុងពាណិជ្ជកម្ម ៣៧.៦២៧.០០៥ ដុល្លារអ៊ិយអេស
- ចំណាយក្រៅពាណិជ្ជកម្ម ១,៣៨៧.៦៥៤ ដុល្លារអ៊ិយអេស
- ចំណាយសំរាប់ទុនអាជីវកម្មធនាគារ : ៣.៥០០:០០០ ដុល្លារអ៊ិយអេស
- គ្រោងសំរាប់អគ្គិសនីឡូតិ៍សណ្ឋាគារ : ៣០០.០០០ ដុល្លារអ៊ិយអេស
- ត្រៀមបំរុងសំរាប់ចំណាយផ្សេងៗ : ៣.១៨៥.៣៤១ ដុល្លារអ៊ិយអេស ដើម្បីធ្វើការនាំចូលសំភារៈបរិក្ខារវត្ថុធាតុដើម និងគ្រឿងបន្លាស់ផ្សេងៗ បំរើតម្រូវការចាំបាច់នោះ គ្រប់ក្រសួងស្ថាប័ន និង អង្គភាពពាក់ព័ន្ធ ត្រូវត្រិះរិះពិចារណា ការប្រើប្រាស់អោយចំមុខសញ្ញា និង គិតគូរថ្លឹងថ្លែងអោយបានហ្មត់ចត់ ពីប្រសិទ្ធភាពសេដ្ឋកិច្ច នៃសម្ភារៈនាំចូល ។

ប្រការ ៤: ចំពោះទុនអាជីវកម្មធនាគារ ដែលរដ្ឋបានផ្តល់អោយនោះធនាគារពាណិជ្ជកម្មក្រៅប្រទេស មានភារកិច្ចអោយខ្ចី ចងការ ឬ លក់ផ្តាច់ អោយបណ្តាសំណុមពរផ្សេងៗ:

- សិប្បកម្មដែលទទួលផែនការផលិតរបស់រដ្ឋ ដើម្បីនាំចូលវត្ថុធាតុដើម មកបំរើផលិតកម្មក្នុងក្របខ័ណ្ឌមុខទំនិញ បរិមាណដែលមានឯកភាព ពីក្រសួងផែនការ និង ក្រសួងឧស្សាហកម្ម។ ចំនួនរូបិយប័ណ្ណដែលអោយខ្ចីចងការ ត្រូវមានមតិសំរេចពីក្រុមប្រឹក្សារដ្ឋមន្ត្រី ។
- សមាជិកគណៈប្រតិភូ ទៅបំពេញបេសកកម្មនៅបរទេសនូវចំនួនទឹកប្រាក់សមស្របតាមការកំណត់របស់ក្រសួងហិរញ្ញវត្ថុ បន្ថែមលើរបបដែលរដ្ឋផ្តល់អោយ ។

- សំរាប់ការនាំចូលសៀវភៅឯកសារ បំរើការរៀនសូត្ររបស់អ្នកស្រាវជ្រាវ និង និស្សិត ដោយផ្ទាល់ ។

— ការចំណាយទិញសំបុត្រយន្តហោះ ។

— ចំណាយក្នុងការទូទាត់ប្រាក់បៀវត្សអ្នកជំនាញការបរទេស ។

ប្រការ៥ : បណ្ដាក្រសួង ស្ថាប័ន និង អង្គភាព ដែលទទួលគំរិតកំណត់ចំណាយដោយទុនផ្ទាល់របស់អង្គភាព ត្រូវបើកគណនី នៅធនាគារពាណិជ្ជកម្មក្រៅប្រទេស ហើយយកទុនផ្ទាល់នោះទៅទិញរូបិយប័ណ្ណខ្វែងពីធនាគារ តាមអត្រាអាជីវកម្មរបស់ធនាគារ ជាធរមាន ។ ក្នុងករណីទុនផ្ទាល់របស់អង្គភាពមិនគ្រប់គ្រាន់ ត្រូវខ្ចីចងការពីធនាគារ ។ ចំពោះអង្គភាពទទួលគំរិតកំណត់ចំណាយដោយទុនថវិការដ្ឋផ្ដល់ ត្រូវបានទូទាត់តាមអត្រាផ្ទៃក្នុងរបស់រដ្ឋកំណត់ ។

ប្រការ៦ : គ្រប់ក្រសួង ស្ថាប័ន និង អង្គភាពពាក់ព័ន្ធ ដែលបានទទួលរូបិយប័ណ្ណសំរាប់ចំណាយនាំចូល ត្រូវអនុវត្តចុះកិច្ចសន្យាជាមួយក្រុមហ៊ុនកាំប៉ិចស៊ីម តាមខ្លឹមសារអនុក្រឹត្យលេខ ៩១ អ.ន.ក្រ ចុះថ្ងៃទី ២៩-០៩-១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្ដីពីទំនិញនាំចូល លក្ខខ័ណ្ឌធ្វើប័ណ្ណបញ្ជាទិញ និងការចុះកិច្ចសន្យាការទទួល និងការប្រគល់ការសងប្រាក់ ការទូទាត់ និងការតវ៉ា ។ ចំពោះការបញ្ជាទិញគ្រឿងសម្ភារៈបរិក្ខារធំ ក្រុមហ៊ុនកាំប៉ិចស៊ីម ត្រូវអនុវត្តការដេញថ្លៃជាមួយក្រុមហ៊ុនបរទេស ដោយមានការចូលរួមពីអង្គភាពបញ្ជាទិញ ។

ប្រការ៧ : ក្រសួងហិរញ្ញវត្ថុ.និង.ធនាគារជាតិ ត្រូវផ្សព្វផ្សាយសេចក្ដីណែនាំ អនុវត្តការទិញលក់រូបិយប័ណ្ណ និងគោលការណ៍ នៃការប្រើប្រាស់ទុនសំរាប់ទិញរូបិយ–ប័ណ្ណតាមអត្រាជាធរមានក្នុងការធ្វើអាជីវកម្មលក់-ទិញរបស់ធនាគារ ។

ប្រការ៨ : រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម ក្រសួងហិរញ្ញវត្ថុ ព្រមទាំងប្រធានធនាគារជាតិនៃប្រជាជនកម្ពុជា ត្រូវមានវិធានការសម្រេចក្នុងការចាត់តាំងអនុវត្ត សេចក្ដីសំរេចនេះធានាសំណូមពរប្រើប្រាស់អោយបានទាន់ពេលវេលា ។

សេចក្ដីសំរេចនេះ មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ទា សុន

តារាងកំណត់ផែនការចំណូលរូបិយប័ណ្ណខ្លាំងឆ្នាំ១៩៩០

« ភ្ជាប់សេចក្ដីសម្រេចលេខ ២៨ សសរ ចុះថ្ងៃទី ២៣ - ០២ - ១៩៩០ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី »

	ក្រសួង - អង្គភាព ក	ចំណូល		
		ក្នុងពាណិជ្ជកម្ម	ក្រៅពាណិជ្ជកម្ម ២	សរុប ៣
I	ក្រសួងពាណិជ្ជកម្ម :	១២.៧០៧.០០០	៦៥៦.០០០	១៣.៣៦៣.០០០
	១ - នាយកដ្ឋាននីហរណ៍ - អាហរណ៍	៧.៨០០.០០០		៧.៨០០.០០០
	- នាំចេញសំឡី - ៣០០ តោន	២១០.០០០		
	- នាំចេញកៅស៊ូ ៨.១០០ តោន	៤.៥៩០.០០០		
	- នាំចេញទំនិញផ្សេង ៗ	៣.០០០.០០០		
	២ - នាយកដ្ឋានស្បៀងមជ្ឈិម	១.១០៤.០០០		១.១០៤.០០០
	- នាំចេញពោត ១៣.០០០ តោន	១.១០៤.០០០		
	៣ - នាយកដ្ឋានប្រមូលទិញ	៤.៩៩៩.០០០		៤.៩៩៩.០០០
	- នាំចេញសណ្ដែកបាយ ៣.៥០០ តោន	១.០៥០.០០០		
	- នាំចេញសណ្ដែកសៀង ៥.១០០ តោន	១.៧៥០.៣០០		
	- នាំចេញគ្រាប់ឈូក ៥០០ តោន	២០០.០០០		
	- នាំចេញម្រេច ៣០ តោន	៦០.០០០		
	- នាំចេញល្ហុងប្រេង ៣០០ តោន	៦០.០០០		
	- នាំចេញស្វាយចន្ទី ៣០០ តោន	១២០.០០០		
	- នាំចេញល្ង ១.៦០០ តោន	៦៤០.០០០		
	- នាំចេញទំនិញផ្សេង ៗ	១.១១៨.៧០០		
	៤ - សណ្ឋាគារមិត្តភាព	៣០០.០០០		៣០០.០០០
	- លក់សេវផ្ទះពិមណ្ឌល//	៣០០.០០០		

	ក	១	២	៣
	៤ - សណ្ឋាគារសាមគ្គី :	៤០០.០០	៥១៤.០០០	
	- លក់កេសផ្ទះពីមណ្ឌល ៈ	៤០០.០០០		
	- ឈ្នួលបន្ទប់		៥១៤.០០០	
	៦ - ធនាគារ ឥណទាន	២០០.០០០		២០០.០០០
	៧ - សហគ្រាសផ្លូវផ្សេងរថយន្ត	៥០.០០០		៥០.០០០
	៨ - បណ្ដាអគ្គិភាពក្រោមទាំង ជួលផ្ទះអោយឯកជន		១៥០.០០០	១៥០.០០០
II	- ក្រសួងឧស្សាហកម្ម	២៨៥.០០០		
	- ផលពាងចក្រទឹកដោះគោ		១០០.០០០	
	- ផលអគ្គិសនីរោងចក្រធុរយោ		១៨.០០០	
	- នាំចេញកន្ទក់ឆ្អិន ៣០០ តោន	១៥.០០០		
	- នាំចេញស្បែកគោ ៤០០តោន	២៥០.០០០		
III	- ក្រសួងកសិកម្ម	៧.១០០.០០០		៧.១០០.០០០
	១ - នាយកដ្ឋានរុក្ខា-ប្រមាញ់			
	- លក់ឈើមូល - ឈើកែច្នៃ	៦.១០០.០០០		៦.១០០.០០០
	- នាយកដ្ឋានជលផល			
	- នាំចេញផលនេសាទ	១.០០០.០០០		១.០០០.០០០
IV	ក្រសួងគមនាគមន៍ :	៨៥០.០០០	៤៣០.០០០	១.៣៨០.០០០
	១ - នាយកដ្ឋានប្រៃសណីយ៍	៤០០.០០០		៤០០.០០០
	- លក់តែមប្រៃ- សេវាកម្ម	៤០០.០០០		
	២ - នាយកដ្ឋានកំពង់ផែ		៤០០.០០០	៤០០.០០០
	- ភ្នំពេញ		១៥០.០០០	
	- កំពង់សោម		២៥០.០០០	
	៣ - នាយកដ្ឋានកាសាប	៤០០.០០០		៤០០.០០០
	- លក់ប្រេងឥន្ធនៈ - សេវាកម្ម	៤០០.០០០		
	៤ - នាយកដ្ឋានសម្ភារៈ	៥០.០០០		៥០.០០០
	- អាជីវកម្មលើរថយន្តនាំចូល	៥០.០០០		
	៥ ឈ្នួលបន្ទប់សណ្ឋាគារ		៣០.០០០	៣០.០០០
	- ក្រសួងការបរទេស	៩០០.០០០	៤៥០.០០០	១.៣៥០.០០០

	ក	១	២	៣
	១ សណ្ឋាគារ ស	២០០.០០០	៣៥០.០០០	៥៥០.០០០
	- លក់ភេសជ្ជៈភោជនីយដ្ឋាន //	២០០.០០០		
	- ឈ្នួលបន្ទប់		៣៥០.០០០	
	២ - នាយកដ្ឋានជំនួយការអន្តរជាតិ	៤០០.០០០	១០០.០០០	៥០០.០០០
	- សេវាកម្ម- លក់ប្រេងឥន្ធនៈ	៤០០.០០០		
	- ឈ្នួលរថយន្ត		១០០.០០០	
VI	ក្រសួងឃោសនាការ- វប្បធម៌		៦២.០០០	
	១ - នាយកដ្ឋានភាពយន្ត			៣.០០០
	- លក់ខ្សែភាពយន្ត		៣.០០០	
	២ សម្ព័ន្ធអាគន្តុកៈ			៣០.០០០
	- ទស្សនាវដ្ដីរូបភាព- សេវាកម្មភ្ញៀវបរទេស		៣០.០០០	
	៣ នាយកដ្ឋានសិល្បៈ			១០.០០០
	- សំដែងសិល្បៈជូនភ្ញៀវបរទេស		១០.០០០	
	៤ មជ្ឈមណ្ឌលផលិតវត្ថុសិល្បៈ			៥.០០០
	- លក់- នាំចេញវត្ថុសិល្បៈ		៥.០០០	
	៥ អាគារបោះពុម្ពផ្សាយ			១.០០០
	- លក់រូបភាព		១.០០០	
	៦ អាគារចែកផ្សាយ		៣.០០០	៣.០០០
	៧ នាយកដ្ឋានអភិរក្ស			១០.០០០
	- ទេសចរទស្សនាប្រាសាទ - បុរាណ - សារមន្ទីរ		១០.០០០	
VII	ក្រសួងការពារប្រទេស		១.០៥០.០០០	១.០៥០.០០០
	១ នាយកដ្ឋានអាកាសចរ			១.០០០.០០០
	- សេវាកម្មដឹកជញ្ជូន		១.០០០.០០០	
VIII	២ - ឈ្នួលបន្ទប់សណ្ឋាគារ		៥០.០០០	៥០.០០០
	ធនាគារជាតិ	១០០.០០០	៥០.០០០	៧.៦៥០.០០០
	១ ផ្សារលក់គ្រឿងអលង្ការ	១០០.០០០		១០០.០០០

	ក	១	២	៣
	២ អាជីវកម្មឡូត្រាក់			៧.៥០០.០០០
	៣ សណ្ឋាគារ គុសិកខៀប		៤០.០០០	៤០.០០០
IX	ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី			
	- សណ្ឋាគារសុខាល័យ និង សកល		១៣០.០០០	១៣០.០០០
X	ទេសចរណ៍ភ្នំពេញ	៥២០.០០០	១.៩៨៤.០០០	១.៧០៤.០០០
	១ សណ្ឋាគារមនោរម្យ	៣៧០.០០០	៨០០.០០០	៦៧០.០០០
	- លក់ភេសជ្ជៈ	៣៧០.០០០		
	- ឈ្នួលបន្ទប់		៨០០.០០០	
	២ ម៉ូតែលកាំកូនីយ៉ាណា	១៤០.០០០	១០០.០០០	២៤០.០០០
	- លក់ភេសជ្ជៈ	១៤០.០០០		
	- ឈ្នួលបន្ទប់		១០០.០០០	
	៣ - ភោជនីយដ្ឋានមិត្តភាព	១០.០០០		១០.០០០
	៤ - ទេសចរណ៍ទឹកជ្រោះ		១០០.០០០	១០០.០០០
	៥ - សណ្ឋាគារកាំកូនីយ៉ាណា		៨០០.០០០	៥០០.០០០
	៦ - សណ្ឋាគារអាស៊ីនិងសន្តិភាព		៤០.០០០	៤០.០០០
	៧ - ល្ខោនវិទ្យា «១២កន្លង»		១៤៤.០០០	១៤៤.០០០
XI	- ខេត្ត ក្រុងនាំចេញក្រៅ និង លើសផែនការអាជីវកម្ម	២.២៩០.០០០០	៣១០.០០០	២.០០០.០០០
	១ - ខេត្តសៀមរាប	៥០.០០០	១៥០.០០០	២៦០០.០០០
	- សេវាកម្មទេសចរណ៍		១៥០.០០០	
	- នាំចេញកូនក្រពើ	៦០០.០០		
	២ - ខេត្តកោះកុង	៤៥០.០០០	៦០.០០០	៥១០.០០០
	- នាំចេញផលនេសាទ និង កសិផលផ្សេងៗ	៤៥០.០០០		
	- ឈ្នួលបន្ទប់សណ្ឋាគារ		៦០.០០០	
	៣ - ខេត្តរតនគិរី	៥០០.០០០		៥០០.០០០
	- នាំចេញកៅស៊ូ	៥០០.០០០		

ក	១	២	៣
៤ - ក្រុងកំពង់សោម	*៣០០.០០០*	*១០០.០០០*	*៤០០.០០០*
- នាំចេញកៅស៊ូ កសិផល-ផលនេសាទ	៣០០.០០០		
- ឈ្នួលបន្ទប់សណ្ឋាគារ		១០០.០០០	
ខេត្តពោធិ៍សាត់	*១០០.០០០*		*១០០.០០០*
- នាំចេញកសិផល-អនុផលផ្សេង ៗ	១០០.០០០		
៦ - ខេត្តកំពង់ចាម	*៤០០.០០០*		*៤០០.០០០*
- នាំចេញកសិផល	៤០០.០០០		
៧ - ខេត្តស្ទឹងត្រែង	*៦០.០០០*		៦០០.០០០
- នាំចេញអនុផលផ្សេង ៗ	៦០.០០០		
៨ - ខេត្តកំពត	*១០.០០០*		១០.០០០
- នាំចេញផលិត-ផលនេសាទ	១០.០០០		
សរុប	២៩.៩០៤.០០០	៦.៤៥៩.០០០	៤០.៧៦២.០០០

ក្នុងនេះ:

ទុនអាជីវកម្មធនាគារជាតិ _ _ _ _ _ _ _ _ ៧ ៥០០.០០០

ភ្នំពេញ, ថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ១៩៩០

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ជា សុទ្ធ

កំរិតកំណត់ចំណាយថវិកាមូលបត្រប័ណ្ណខ្លាំងឆ្នាំ ១៩៩០
ភ្ជាប់សេចក្តីសំរេចលេខ ២៨ សសរ ចុះថ្ងៃទី ២៣-០២-១៩៩០
របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

ឯកតា : ស៊ុយរ៉ង់រៀល

ល.រ	ក្រសួង - អង្គភាព ក	កំរិតកំណត់ ១	ទុនថវិកាផ្តល់ ២	ទុនអង្គភាពផ្ទាល់ ៣	សេចក្តីផ្សេងៗ ៤
I	- ក្រសួងឧស្សាហកម្ម :	១៣.១៣០.១០៥	៧.៧៤៥.៨៦០	៥.៣៨៤.២៤៥	
	១ - សម្ព័ន្ធបារីកម្ពុជា :	២.៦៦៩.២៤៥		២.៦៦៩-២៤៥	
	- វត្ថុធាតុដើមផលិតបារី	១.៦៦៩.២៤៥		១.៦៦៩.២៤៥	បន្ទុយនាំចូលសារធាតុ
	- ម៉ាស៊ីន និងគ្រឿងបន្លាស់	១.០០០.០០០		១.០០០.០០០	ដោយយកវត្ថុធាតុដើម ឲ្យរៀតណាយផលិតៗ
	២ - សម្ព័ន្ធតម្បាញ	៣.២៤៥.៨៦០	៣.២៤៥.៨៦០		
	- វត្ថុធាតុដើម	១.៦៧៣.៣០០០	១.៦៧៣.៣០០		
	- គ្រឿងបន្លាស់	៣២៦.៧០០	៣២៦.៧០០		
	- វត្ថុធាតុដើមបន្ថែម	១.២៤៥.៨៦០	១.២៤៥.៨៦០		សំរាប់ផលិតផលកងទ័ព

ក	១	២	៣	៤
៣ - ក្រុមហ៊ុនអគ្គិសនី :	៤.៥០០.០០០	៤.៥០០.០០០		
- ម៉ាស៊ីនអគ្គិសនីថ្មី ០៣ គ្រឿង	៤.៥០០.០០០	៤.៥០០.០០០		
៤ - ឧស្សាហកម្មគីមី :	១.៣០០.០០០	១.៣០០.០០០		គិតទាំងវត្ថុធាតុគីមីផលិតសំបកកង់កុំម៉ង់ភាចំនួន ៥.០០០ សំរាប់របស់រដ្ឋធានី
៥ - ឧស្សាហកម្មស្បៀង :	៥៩៩.០០០		៥៩៩.០០០	
- គ្រឿងបន្លាស់	៥០០.០០០		៥០០.០០០	
- វត្ថុធាតុគីមី	៩៩.០០០		៩៩.០០០	
៦ - ឧស្សាហកម្មស្រាស	៥១៦.០០០		៥១៦.០០០	
- វត្ថុធាតុធាតុគីមី-គ្រឿងបន្លាស់	២១៦.០០០		២១៦.០០០	
- ម៉ាស៊ីនបោះពុម្ព ០១ គ្រឿង	៣០០.០០០		៣០០.០០០	
- ក្រសួងកសិកម្ម :	៥.៥១៤.០០០	១.៩៦៤.០០០	៣.៥៥០.០០០	
១ - នាយកដ្ឋានក្សេត្រសាស្ត្រ	២០០.០០០	២០០.០០០		
២ - នាយកដ្ឋានផលិតកម្មបសុព្យាបាល	១០០.០០០	៥០.០០០	៥០.០០០	
ថ្នាំព្យាបាលសត្វ - សំភារៈពេទ្យ	៥០.០០០	៥០.០០០		

ក	១.	២	៣	៤
ថ្លៃលាយចំណីសត្វ – សម្ភារៈ				
ពេទ្យ	៥០.០០០		៥០.០០០	
៣ - ទាយកដ្ឋានគ្រឿងយន្ត	២០០.០០០	២០០.០០០		
- រ៉ូឡូបិតសំរាប់ធន្លល	៦០.០០០	៦០.០០០		
. សម្ភារៈបរិក្ខាររោងជាង	១៤០.០០០	១៤០.០០០		
៤ - ទាយកដ្ឋានសហប្រតិបត្តិការ	៦៦.០០០	៦៦.០០០		
. សម្ភារៈឧបករណ៍	៦៦.០០០	៦៦.០០០		
៥ - ទាយកដ្ឋានសម្ភារៈ	២.៦៣៦.០០០		២.៦៣៦.០០០	
- ផឺ១៦.២០.០ និងផី ១៥.១៥.១៥	២.៣០០.០០០		២.៣០០.០០០	ធ្វើពាណិជ្ជកម្មដោយរដ្ឋមិនបំពេញខាត
- បបកាប់ ២ សោនវែ	៣០០.០០០		៣០០.០០០	
- បិតដំបាញ់ថ្នាំ	៣៦.០០០		៣៦.០០០	
៦ - ទាយកដ្ឋានផលផល	៩០០.០០០		៩០០.០០០	ប្រើប្រាស់ខុសគោលការណ៍ សេចក្តីសំរេចលេខ ៩៣ សសរ ០៨-០៨-១៩៩៣
ក - មន្ត្រីទីស្តីការក្រសួងកសិកម្ម	៣៥.០០០	៣០.០០០		

ក	ខ	គ	ឃ	ង
- ឧបករណ៍សម្ភារៈរោងពុម្ព	៣០.០០០	៣០.០០០		
៨. នាយកដ្ឋានវេទិកា ប្រមាញ់	១.០៨០.០០០	១.០៨០.០០០		
ទិញសាឡុង ០១ គ្រឿង	៣០០.០០០	៣០០.០០០		
- សម្ភារៈតុទូឈើ	៧០៥.០០០	៧០៥.០០០		
- ឧបករណ៍សម្រាប់សហប្រតិបត្តិការសង្វៀត	៧៥.០០០	៧៥.០០០		
- ប្រេងឥន្ធនៈ ១០០ តោន	0	0		ក្រសួងពាណិជ្ជកម្មនាំចូលដោយ
៩. នាយកដ្ឋានជាងសាស្ត្រ	៣៩២.០០០	៣៩២.០០០		
- គ្រឿងឧបករណ៍ម៉ាស៊ីន	៣៩២.០០០	៣៩២.០០០		គ្រឿង១ចំនួនជំនួសដោយការនាំចូលពីសូវៀត
ប្រេងម៉ាស៊ូត	0	0		ក្រសួងពាណិជ្ជកម្មនាំចូលដោយ
- ក្រសួងឃោសនាការ វប្បធម៌	១.៦៩០.០០០	១.៦១៥.០០០	៧៥-០០០	
១. សហគ្រាសសម្ព័ន្ធរោងពុម្ពទី ១ ទិញម៉ាស៊ីនបោះពុម្ពនិងម៉ាស៊ីនកាត់ក្រដាស ០៥ គ្រឿង	១-៦០០.០០០	១ ៦០០.០០០		ក្នុងនេះម៉ាស៊ីនកាត់ក្រដាស ០១ គ្រឿងសម្រាប់អាគារបោះពុម្ពផ្សាយ

ក	១	២	៣	៤
២ . នាយកដ្ឋានភាគយន្ត	៣០.០០០		៣០.០០០	
- ទិញម៉ាស៊ីន និងគ្រឿងបន្លាស់ផ្សេងៗ				
៣ . មជ្ឈមណ្ឌលផលិតវត្ថុសិល្បៈ	១៥.០០០	១៥.០០០		
- ម៉ាស៊ីនសំភារៈយកទានសំការៈ និងវត្ថុធាតុដើម				
៤ . អគ្គភាពសំភារៈ	៤៥.០០០		៤៥.០០០	- ស្នាន់ ៥ គោនយកពីក្រសួងឧស្សាហកម្មតាមការនាំចូលពីបណ្ដាល ។
- សំភារៈវត្ថុធាតុដើមសំរាប់ជាះកុម្ម				
- ក្រសួងគមនាគមន៍	៤.៣៣២.០០០	៣.៩២៧.០០០	៤៥៥.០០០	
១ . នាយកដ្ឋានចរាចរណ៍	១៥០.០០០		១៥០.០០០	
- រថយន្តដឹកមនុស្ស ៣ គ្រឿង សំរាប់អាជីវកម្មដឹកភ្ញៀវ	៥០.០០០		៥០.០០០	
- នាំចូលគ្រឿងបន្លាស់ថែទាំបំពង់បង្ហូរ	១០០.០០០		១០០.០០០	- ជួនផ្ដើមដោយការពិចារណា
២ . នាយកដ្ឋានប្រៃសណីយ៍	៣០០.០០០	២០០.០០០	១០០.០០០	

ក	១	២	៣	៤
- គ្រឿងបន្ទាស់សំភារៈបច្ចេកទេស	២០០.០០០	២០០.០០០		
សង់ផ្ទះផ្កាយរណប និង				
ប្រៃសណីយ៍	១០០.០០០		១០០.០០០	ចំណាយក្រោះការណ៍ផ្ទុកមួ
៣ . ទាយកដ្ឋានកំពង់ផែ	១៣០.០០០		១៣០.០០០	
ទិញសំភារៈគ្រឿងបន្ទាស់លើកដាក់				
: ផែក្រុងកំពង់សោម	១០០.០០០		១០០.០០០	
. ផែក្រុងភ្នំពេញ	៣០.០០០		៣០.០០០	
៤ - សហគ្រាសបូមស្ការ :	៥០.០០០	៥០.០០០		
- គ្រឿងបន្ទាស់ទាវាបូមដី				
៥ . ក្រុមហ៊ុនដឹកជញ្ជូនផ្លូវទឹក	១០០.០០០	១០០.០០០		
. គ្រឿងបន្ទាស់សំភារៈនាវា				
៦ . ក្រុមហ៊ុនស្មាន - ផ្តល់	១.៤៥៣.០០០	១.៤៥៣.០០០		
គ្រឿងបន្ទាស់ម៉ាស៊ីនថ្មី	៨០០.០០០	៨០០.០០០		
- ទិញសាឡាងចម្លង ០១ គ្រឿង				
ចំណុះ ១៣០ តោន .	៩៥០.០០០	៩៥០.០០០		

ក	១	២	៣	៤
បរិក្ខាសំរាប់បំរើការសិក្សា ផ្ទះសំរាប់ការិយាល័យស្រាវជ្រាវ និងបន្ទប់ពិសោធន៍	២៥០.០០០	២៥០.០០០		
- ឧបករណ៍គ្រូគតិវិទ្យាផ្ទះ	៥៧.០០០	៥៧.០០០		- ផ្តល់ជំនួសដោយការនាំចូលពីសូវៀត
- គ្រឿងចក្រផ្សេងៗ	0	0		
៣ ក្រុមហ៊ុនផ្លូវដែក :	<u>២.១២០.០០០</u>	<u>២.១២០.០០០</u>		
- គ្រឿងបន្លាស់ក្បាលរទេះភ្លើង	៥០០.០០០	៥០០.០០០		
ជីកផលក្នុងក្បាលរថភ្លើងពីឆេក	៦០.០០០	៦០.០០០		
ជម្លាយកង់រថភ្លើងពីឥណ្ឌា	៥៤០.០០០	៥៤០.០០០		
ទូរដឹកអ្នកដំណើរ	៧២០.០០០	៧២០.០០០		
៤ នាយកដ្ឋានសំភារៈ :	<u>៤៣៥.០០០</u>		៤៣៥.០០០	
- សំភារៈប្រើប្រាស់ កុំព្យូទ័រ-ហ្វូតូកូពី	៧.០០០		៧.០០០	
- ខេមនូសំរាប់អាជីវកម្ម-គ្រឿងបន្លាស់	៤២៨.០០០		៤២៨.០០០	- ទិញ ឬ ទិញពីធនាគារ

	ក	១	២	៣	៤
V.	ទីភ្នាក់ងារសារព័ត៌មានកម្ពុជា	១៥០.០០០	១៥០.០០០		
	សំភារៈបំពាក់ការផ្សាយ - ទទួលដំណឹងតាមរលកធាតុអាកាស	៤០.០០០	៤០.០០០		
	សំភារៈបោះពុម្ព	២៥.០០០	២៥.០០០		
	សំភារៈម៉ាស៊ីនអំពូលភ្លើង	១៣.០០០	១៣.០០០		ដោយគិតទៅតាមតំរូវការរបស់កាសែតកម្ពុជា
	សំភារៈពិសោធន៍ផលិតរូប	៣២.០០០	៣២.០០០		
	សំភារៈការិយាល័យ	៤០.០០០	៤០.០០០		
VI.	ក្រសួងសុខាភិបាល : វត្ថុធាតុដើម - ឱសថ - សំភារៈបរិក្ខារពេទ្យ	៦.០០០.០០០	៥.០០០.០០០	១.០០០.០០០	
VII.	កាសែតកម្ពុជា	៣០.០០០	៣០.០០០		សំភារៈជួយចំនួនពិញពី " អេសប៉េកា " និង គូប្រកួតដ៏ជាមួយ " អេសប៉េកា "
VIII.	អគ្គិសនី និង ទូរទស្សន៍	២២០.៦០០	២២០.៦០០		

	ក	១	២	៣	៤
	- គ្រឿងបន្លាស់វិទ្យុ	១១៨.៦០០	១១៨.៦០០		
	- គ្រឿងបន្លាស់ទូរទស្សន៍	១០២.០០០	១០២.០០០		
IX	- អគ្គនាយកដ្ឋានទេសចរណ៍	0	0		- រង់ចាំតនុក្រឹត្យ ដើម្បីពិនិត្យផ្ដល់
X	- អគ្គនាយកដ្ឋានសំណង់	៧.០០០		៧.០០០	- ចំណាយក្រោមគណៈកម្មការទិញពីធនាគារ
XI	ផារឯកសារបច្ចេកទេសសំណង់ - អគ្គនាយកដ្ឋានបំពានកៅស៊ូ	១.០០០.០០០	១.០០០.០០០		- អាជ្ញាធរធានាទេសចរណ៍របស់អគ្គភាព
XII	សំភារៈបរិក្ខា-វត្ថុធាតុដើម និងគ្រឿងបន្លាស់ម៉ាស៊ីនភ្លើង				
	ក្រសួងពាណិជ្ជកម្ម :	៣.០០០.០០០		៣.០០០.០០០	
	ប្រេងម៉ាស៊ូត	៦០០.០០០		៦០០.០០០	
	ប្រេងឥន្ធនៈ	២.៤០០.០០០		២.៤០០.០០០	
XIII	ក្រសួងការបរទេស	៣០១.៦៨៤	៣០១.៦៨៤		
	គ្រឿងបន្លាស់ជួសជុលអគារស្ថានទូត ស.	២០.០០០	២០.០០០		

	ក	១	២	៣	៤
	- ចំណាយស្ថានទូត និង សំណង់ផ្សេងៗ	២៨១.៦៨៤	២៨១.៦៨៤		- ចំណាយក្រៅពាណិជ្ជកម្ម
	- បៀវត្ស	៦.៦៨៤	៦.៦៨៤		
	- សំរាប់អគ្គភាព	២៧៥.០០០	២៧៥.០០០		
	- ស្ថានទូតនៅឆេកូ ទិញរថយន្តម៉ាកស៊ីវ៉ែស ០១ គ្រឿង	២៣.០០០	២៣.០០០		
	- កុងស៊ុលនៅហូជីមិញ ទិញរថយន្តនីសាន់ ០១ គ្រឿង	១១.០០០	១១.០០០		
	- ស្ថានទូតនៅវៀងច័ន្ទទិញរថយន្ត ០១ គ្រឿង	២៥.០០០	២៥.០០០		
XIV	- ក្រសួងការបរទេស	២៨០.០០០	២៨០.០០០		- ចំណាយក្រៅពាណិជ្ជកម្ម
	- ឧបករណ៍ទាក់ទងយន្តហោះ និង ម៉ាស៊ីនត្រជាក់	២០០.០០០	២០០.០០០		
XV	ផ្លូវអាកាសយន្តហោះ	៨០.០០០	៨០.០០០		
	គណៈប្រតិភូចេញក្រៅ	៣០០.០០០	៣០០.០០០		- ចំណាយក្រៅពាណិជ្ជកម្ម
XVI	ផារទស្សនាវដ្ដី :	១៥.០០០	១៥.០០០		- ចំណាយក្រៅពាណិជ្ជកម្ម

	ក	១	២	៣	៤
	– ក្រសួងផែនការ	២.០០០	២.០០០		
	– ក្រសួងពាណិជ្ជកម្ម	២.០០០	២.០០០		
	– ក្រសួងហិរញ្ញវត្ថុ	១.០០០	១.០០០		
	– ធនាគារជាតិ	២.០០០	២.០០០		
	– សារព័ត៌មាន “ អេសប៉េកា ”	១២.០០០	១២.០០០		
VII	– ក្រុមហ៊ុនក្រចៅកម្ពុជា	៦០.០០០		៦០.០០០	
	– ទិញប្រេងបន្ទន់ក្រចៅ				
VIII	– ទុនអាជីវកម្មរបស់ធនាគារ	៣.៥០០.០០០		៣.៥០០.០០០	
XIV	ការនាំចូលរបស់ខេត្ត–ក្រុង	២.២៥០.០០០		២.២៥០.០០០	
XX	– គ្រោងអភិវឌ្ឍន៍សណ្ឋាគារ	៣០០.០០០		៣០០.០០០	
XXI	– ត្រៀមបំរុងចំណាយផ្សេងៗ	៣.១៨៥.៣៨១			
	សរុបចំណាយ	៤២.០០០.០០០	២៣.០៧៣.៦១៤	១៩.៣៨៣.២៨៥	

ភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩០

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និងត្រា

ជា សុទ

៣ - សេចក្តីណែនាំ

ភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩០

សេចក្តីណែនាំលេខ ០១ សណន
ស្តីពីការបង្កើនប្រសិទ្ធភាពគ្រប់គ្រងផលិតកម្មសត្វ និងផលិតផលមានដើមកំណើតពីសត្វ

ជាង ១១ ឆ្នាំ ក្រោយទឹកដីត្រូវបានរំដោះ អាស្រ័យដោយគោលនយោបាយត្រឹមត្រូវរបស់បក្ស និងរដ្ឋ ការចិញ្ចឹមសត្វមានការរីកលូតលាស់ជាលំដាប់ ឆ្លើយតបបាននឹងតម្រូវការចេះតែកើនឡើងក្នុងការងារបង្កបង្កើនផលផលិតកម្ម និងជីវភាពរស់នៅរបស់ប្រជាជនយើង និងមានសន្និធិមួយចំនួនលើសពីសេចក្តីត្រូវការក្នុងប្រទេស បញ្ជាក់ច្បាស់ពីតួនាទីកាន់តែកើនឡើងរបស់ផលិតកម្មសត្វក្នុងវិស័យសេដ្ឋកិច្ចនិងសង្គមកិច្ច ។ មុខសកម្មនេះហើយបានពង្រីកអោយចំទិសនោះ ពិតជារួមចំណែកក្នុងការបង្កបង្កើនផលទុនជាតិ និងជាប្រភពសំខាន់មួយសំរាប់ប្រមូលរូបិយវត្ថុ ។

ប៉ុន្មានឆ្នាំចុងក្រោយនេះ បានកត់សំគាល់នូវភាពអសកម្មជាច្រើន ដែលមិនត្រឹមតែរារាំងសន្ទុះលូតលាស់នៃសត្វបសុកម្មប៉ុណ្ណោះ ថែមទាំងអាចបណ្តាលអោយផ្នែកសកម្មភាពនេះចុះអន់ខ្សោយ បង្កនូវផលវិបាកមិនអោយទាន់ស្ពានបានចំពោះខឿនសេដ្ឋកិច្ចជាតិទៅអនាគត ។ បាតុភាពទាំងនេះផ្តើមចេញពីការគិតគូរ និង ទង្វើខុសឆ្គង ព្រមទាំងការយល់ដឹងមិនទាន់ត្រឹមត្រូវមួយចំនួន :

- ការគ្រប់គ្រងផលិតកម្មសត្វ និងផលិតផលមានដើមកំណើតពីសត្វ ដែលជាសមត្ថកិច្ចផ្ទាល់របស់ក្រសួងកសិកម្មនោះ មិនទាន់ស្ថិតក្នុងសណ្តាប់ធ្នាប់ច្បាស់លាស់ ។
- សកម្មភាពសេដ្ឋកិច្ច និង ពាណិជ្ជកម្ម ខ្វះការទទួលខុសត្រូវរបស់ស្ថាប័ននិងមូលដ្ឋានមួយចំនួន ។
- ទង្វើខុសឆ្គងរបស់បុគ្គលមួយចំនួន ។

ភាពអនាធិបតេយ្យទាំងនេះ ជះឥទ្ធិពលអាក្រក់មិនតិចទេដល់ផលិតកម្ម និងជីវភាពរបស់ប្រជាជន ធ្វើអោយថ្លៃសត្វ និង ផលិតផលមានដើមកំណើតពីសត្វកើនឡើងខ្ពស់ និង ក្នុងសង្កាត់រហ័សគួរព្រួយបារម្ភ ហើយចលនានាំសត្វចេញទៅក្រៅប្រទេសដោយលួចលាក់ និងគ្មានផែនការច្បាស់លាស់ នឹងនាំមកបច្ច័យអាក្រក់ជាច្រើនដូចជា : ខ្វះពូជ-ខ្វះកំលាំងអូសទាញ-ខ្វះប្រភពម្ហូបអាហារ...... ។

គួរគូសបញ្ជាក់ថា ការចិញ្ចឹមសត្វមិនមែនជាសកម្មភាពបន្ទាប់បន្សំទេ វាផ្តើមចេញពីលក្ខខណ្ឌ

ចាំបាច់នៃជីវភាពរស់នៅរបស់ប្រជាជនផ្ទាល់ ។ អាស្រ័យហេតុនេះ មន្ទីរនិងខិតខំជំរុញ និងពង្រីកទូលាយការចិញ្ចឹមសត្វគ្រប់ប្រភេទ តម្លើងប្រសិទ្ធភាពគ្រប់គ្រង និងការពារអោយបានល្អ ដោយយកចិត្តទុកដាក់អនុវត្តវិធានការសំខាន់ពីរ :

១- អប់រំអោយគ្រប់ថ្នាក់ គ្រប់ផ្នែក ប្រជាជនយើងយល់ច្បាស់ពីតួនាទី សារសំខាន់ចំពោះមុខ និង យូរអង្វែងរបស់ការចិញ្ចឹម និងពីផលប្រយោជន៍ ព្រមទាំងតំលៃរបស់សត្វ និងផលិតផលរបស់សត្វ ចំពោះគ្រួសារ ចំពោះមូលដ្ឋាន និង ចំពោះសង្គម ។

២- ណែនាំនិងខិតខំគោរពអោយបានល្អច្បាប់ និង បណ្តាគោលការណ៍ស្តីពីការគ្រប់គ្រងការពារផលិតកម្មសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ។

ក្នុងន័យនេះក្រុមប្រឹក្សារដ្ឋមន្ត្រី សូមផ្តើការណែនាំដូចតទៅ :

ក្រសួងកសិកម្មត្រូវយកចិត្តទុកដាក់បំផុសលើកទឹកចិត្ត និងពង្រីកការចិញ្ចឹមសត្វទូទាំងប្រទេស ព្រមទាំងបង្កើនប្រសិទ្ធភាពគ្រប់គ្រងផលិតកម្ម និង ផលិតផលមានដើមកំណើតពីសត្វអោយមានសណ្តាប់ធ្នាប់ល្អ ។

គ្រប់ខេត្ត-ក្រុង ត្រូវមានវិធានការទប់ស្កាត់ចរាចរខុសច្បាប់របស់សត្វ និងផលិតផលពីសត្វអោយបានម៉ឺងម៉ាត់ ។

បណ្តាអង្គភាពមានសមត្ថកិច្ចនៅតាមព្រំដែន និងច្រកចេញចូលក្នុងនិងក្រៅប្រទេស ត្រូវបង្កើនការត្រួតពិនិត្យយ៉ាងដិតដល់រាល់ការដឹកជញ្ជូនសត្វ និងផលិតផលមានដើមកំណើតពីសត្វ ឆ្លងដែនទៅបរទេស និង បង្ក្រាបយ៉ាងតឹងរ៉ឹងរាល់សកម្មភាពដឹកជញ្ជូនលួចលាក់និងខុសច្បាប់ ។

- ចំពោះចរាចរសត្វ និង ផលិតផលមានដើមកំណើតពីសត្វក្នុងប្រទេស សំរាប់បំរើការងារបង្កបង្កើនផល ផលិតកម្ម និង ជីវភាព ត្រូវគោរពអោយបានហ្មត់ចត់ខ្លឹមសារអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីរដ្ឋមន្ត្រី ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ។

- ចំពោះចរាចរសត្វ និង ផលិតផលមានដើមកំណើតពីសត្វចេញទៅក្រៅប្រទេស ត្រូវអនុញ្ញាតតាមផែនការជាក់ស្តែង ចំពោះតែមូលដ្ឋានណាដែលមានសន្និធិលើសពីសេចក្តីត្រូវការ " សល់ពីទុកធ្វើពូជ-កំលាំងអូសទាញ-បរិភោគ និងបំរើផលិតកម្មក្នុងមូលដ្ឋាន " ដោយមានការយល់ព្រមពីក្រុមប្រឹក្សារដ្ឋមន្ត្រីតាមរយៈក្រសួងកសិកម្ម ។

ក្រុមប្រឹក្សារដ្ឋមន្ត្រីសំណូមពរអោយបណ្តាស្ថាប័នមានសមត្ថកិច្ច និងគ្រប់ខេត្ត-ក្រុង លើកកំពស់

ស្មារតីទទួលខុសត្រូវ ទឹកចិត្តអនុវត្តល្អសេចក្តីសំរេចនេះ ដើម្បីបង្កើនប្រសិទ្ធភាពគ្រប់គ្រងផលិតកម្មសត្វ និង ផលិតផលមានដើមកំណើតពីសត្វនៅទូទាំងប្រទេស សំដៅធ្វើអោយការចិញ្ចឹមសត្វមានការរីកចំរើនស័ក្តិសមនឹងតួនាទី និង សារៈសំខាន់របស់វា ក្លាយជាចំណែកដ៏ខ្លាំងមួយ នៃមុខព្រួញស្បៀង រួមចំណែកយ៉ាងសំខាន់ពង្រឹងឡើងនូវសេដ្ឋកិច្ចជាតិ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ជា សុទ

III – ការងារបណ្ដាក្រសួង

១ – ក្រសួងពាណិជ្ជកម្ម

សេចក្ដីសំរេច

ភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩០

សេចក្ដីសំរេច លេខ ០៧១ ពណ គបក សសរ

ស្ដីពី

ថ្លៃទិញអង្ករអប្បហាររបន្ថែម និងរង្វាន់ លើកទឹកចិត្ត សំរាប់រដូវឆ្នាំ ១៩៨៩ – ៩០

– បានឃើញច្បាប់ស្ដីពីការកែប្រែការចាត់តាំងតួនាទី និង ភារកិច្ចរបស់ក្រសួងពាណិជ្ជកម្ម ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៨ ក្រ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៨៩ ។

– យោងសេចក្ដីសំរេចលេខ ១៥១ សសរ ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ ១៩៨៩ របស់ ក្រុមប្រឹក្សារដ្ឋមន្ត្រីស្ដីពីថ្លៃទិញ ថ្លៃប្រគល់ស្រូវឆ្នាំ ១៩៨៩ – ៩០

– យោងសារាចរណែនាំលេខ ០០១ ពណ.គបត.សរណន ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៨៩ របស់ក្រសួងពាណិជ្ជកម្ម ស្ដីពី ថ្លៃ និងរបៀបទិញស្រូវ រដូវឆ្នាំ ១៩៨៩ – ៩០

– យោងលិខិតលេខ ២២៤៩ សជណ.ពហ ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ១៩៩០ របស់ ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ស្ដីពី ករណីថ្លៃស្រូវឡើងទឹក អង្ករក្រហមលាយស

– យោងលិខិតលេខ ១៤៦ សជណ ពហ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩០ របស់ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ស្ដីពីករណីសុំអនុញ្ញាតិកែប្រែថ្លៃទិញអង្ករ ពីកម្មាភិបាល បុគ្គលិក កម្មករ និងប្រជាជនសំរាប់ឆ្នាំ ១៩៨៩ – ៩០

សំរេច

ប្រការ ១ : ថ្លៃទិញអង្ករពីប្រជាជន កម្មាភិបាល បុគ្គលិក និង កម្មករ នៅមាត់ឃ្លាំងរបស់ ផ្នែកពាណិជ្ជកម្មរដ្ឋ " ឃ្លាំងខេត្ត – ស្រុក " សំរាប់រដូវឆ្នាំ ១៩៨៩ – ៩០ មាន ដូចខាងក្រោមនេះ :

ល.រ	ប្រភេទ អង្ករ	ឯកត្តាគិត	ថ្លៃទិញនៅឃ្លាំងរបស់ផ្នែកពាណិជ្ជកម្ម
១	អង្ករស ធម្មតា	គីឡូ	២៥/០០
២	អង្ករប្រភេទស្រូវឡើងទឹក អង្ករស	-	២៥/០០
៣	អង្ករប្រភេទស្រូវឡើងទឹក អង្ករក្រហម	-	២០/០០
៤	អង្ករប្រភេទស្រូវឡើងទឹកអង្ករក្រហមលាយស	—	២៣/០០
៥	អង្ករប្រភេទស្រូវគុណភាពនាំចេញ	—	២៥/៥០
៦	អង្ករដំណើបស	—	២៧/០០
៧	អង្ករដំណើបខ្មៅ	-	២៥/០០

ប្រការ២: ចំពោះថ្លៃទិញអង្ករនៅរដ្ឋ ឬ សាខាពាណិជ្ជកម្មសមូហភាព ឃុំ-សង្កាត់ប្រគល់សិទ្ធិជូនខេត្ត-ក្រុងកំណត់ជាក់ស្តែង ផ្អែកលើមូលដ្ឋានថ្លៃខាងលើ ដកកំរៃប្រមូលទិញដែលត្រូវជូនឃុំ-សង្កាត់ ។

ប្រការ៣: ថ្លៃប្រគល់អង្ករ ដែលទិញបានតាមមុខសញ្ញានេះជូនមជ្ឈិម ឬ ជូនខេត្ត-ក្រុងតាមផែនការរបស់មជ្ឈិម គឺអនុវត្តស្មើនឹងថ្លៃទិញស្រូវ បូកអប្បហារបន្ថែម បូកនឹងរង្វាន់លើកទឹកចិត្ត ចែកនឹងសមាមាត្រកិនអង្ករ ៦៤ ភាគរយ ។

ប្រការ៤: ខ្ទង់អប្បហារបន្ថែម និង រង្វាន់លើកទឹកចិត្ត ត្រូវបានកំណត់ដូចតទៅ :

ក- ខេត្ត-ស្រុក

ខ្ទង់កំរៃរបស់ការរវាងថ្លៃប្រគល់ និង ថ្លៃទិញដែលបានកំណត់ខាងលើ ត្រូវបានអនុញ្ញាតអោយគិតជា អប្បហារបន្ថែម និង រង្វាន់លើកទឹកចិត្ត ។ ក្នុងទឹកប្រាក់សរុបនេះត្រូវបានអនុញ្ញាតអោយដក ១០០/០០ ក្នុងមួយតោន ជារង្វាន់លើកទឹកចិត្ត ។ ហើយការបែងចែកត្រូវអនុវត្តន៍បែងចែកដូចការងារទិញស្រូវដែរ ។ ឯខ្ទង់ទឹកប្រាក់នៅសល់គឺនេះត្រូវបានគិតជាអប្បហារបន្ថែម របស់ផ្នែកពាណិជ្ជកម្មខេត្ត-ស្រុក ដែលរួមមានចំណាយចរាចរ និង ចំណេញ ។

ខ - ឃុំ-សង្កាត់

ចំពោះទឹកប្រាក់កំរៃប្រមូលទិញរបស់ឃុំ-សង្កាត់ ត្រូវបានកំណត់ជូនខេត្ត-ក្រុងបែងចែកជាក់ស្តែង ដូចការកំណត់ថ្លៃទិញស្រូវនៅឃុំ-សង្កាត់ ក្នុងប្រការ ២ ដែរ ។

ប្រការ៥: សមមិត្តប្រធានក្រុមហ៊ុនស្បៀងមជ្ឈិម សមមិត្តប្រធានមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង សមមិត្តប្រធានមន្ទីរ និង ប្រធាននាយកដ្ឋាន ចំណុះក្រសួងពាណិជ្ជកម្ម មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ។

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

សេចក្តីសំរេចនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ហត្ថលេខា និង ត្រា
គង់ សារឹម

ភ្នំពេញ ថ្ងៃទី ១៥ ខែ០២ ឆ្នាំ ១៩៩០

សេចក្តីសំរេច លេខ ១០៧ ពណគបក សសរ

ស្តីពីថ្លៃលក់ ប្រេងសាំង នាំចូលក្រៅផែនការ

— បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

— បានឃើញច្បាប់ស្តីពី ការកែប្រែ ការចាត់តាំងតួនាទី និង ភារកិច្ចរបស់ក្រសួងពាណិជ្ជកម្មដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៤៥ ក្រ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៨៩

— បានឃើញសេចក្តី សំរេចលេខ ២១២ សសរ ចុះថ្ងៃទី ២៣ . ១២ . ៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

— បានឃើញលិខិត លេខ ១០៨ សណណ ជស ចុះថ្ងៃទី ១៣. ១. ៩០ របស់ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

- តាមសំណើ របស់ក្រុមហ៊ុន សំភារៈ បរិក្ខារ មជ្ឈិម

សំរេច

ប្រការ ១ : កំណត់ថ្លៃលក់ប្រេងសាំង នាំចូលក្រៅផែនការ សំរាប់ចំពោះអោយការប្រើប្រាស់ របស់បណ្តាអង្គភាពរដ្ឋទាំងមជ្ឈិម និងមូលដ្ឋាន ក្រៅពីកំណត់ផែនការរដ្ឋ គឺ ៦៥០០/រ " ហុកសិបប្រាំរយរៀលគត់ " ក្នុង ១ លីត្រ " ថ្លៃប្រគល់នៅមណ្ឌលឃ្លាំងប្រេងរបស់ក្រុមហ៊ុនសំភារៈបរិក្ខារមជ្ឈិម " ។

ប្រការ ២ : ថ្លៃលក់សាំងជូនក្រសួងការពារប្រទេស មហាផ្ទៃ កង មជ្ឈិម ការងារផ្សល-ផុល ផ្ទះស្នាក់ផាយុទ្ធសាស្ត្រ និងការដ្ឋានបក្ស ត្រូវអនុវត្តន៍ តាមសេចក្ដីលេខ ១៨២ សសរ ចុះថ្ងៃទី ១៧.១១.៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និង សេចក្ដីសំរេចលេខ ៦១ សសរ ផកត ចុះថ្ងៃទី ៦.២.៩០ របស់ក្រសួងផែនការ ។

ប្រការ ៣ : ផ្អែកទៅតាមថ្លៃដែលបានកំណត់ក្នុងប្រការ ១ ខាងលើ មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ត្រូវកំណត់ថ្លៃលក់ចេញ អោយបានសមស្រប និង ធានាអាជីវកម្ម ។

ប្រការ ៤ : បណ្ដានាយកដ្ឋាន សេនាធិការ ក្រុមហ៊ុនសំភារៈបរិក្ខារឧស្ម័ន និង មន្ទីរពាណិជ្ជកម្មខេត្ត - ក្រុង ត្រូវទទួលបន្ទុកអនុវត្ត សេចក្ដីសំរេចនេះអោយមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ. រដ្ឋមន្ត្រី

អនុរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

គួច សំ

២ – ក្រសួងកសិកម្ម

សេចក្តីសំរេច

ភ្នំពេញ ថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ១៩៩០

សេចក្តីសំរេចលេខ ០៧៨ សសរ.កសក

ស្តីពីថ្លៃលក់ឧបករណ៍ និង សម្ភារៈកសិកម្ម

រដ្ឋមន្ត្រីក្រសួងកសិកម្ម

– បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

– បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៤ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម ។

– បានឃើញសេចក្តីសំរេច ស្តីពីថានានុក្រមគ្រប់គ្រងថ្លៃរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ១៣៤ សសរ. ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ១៩៨៩ ។

– បានឃើញសេចក្តីសំរេចលេខ ២១២ សសរ. ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការកំណត់ ការកែប្រែអត្រាប្តូររូបិយប័ណ្ណបរទេសសំរាប់អនុវត្តក្នុងការទូទាត់រវាងប្រាក់រៀលជាមួយរូប្លពាណិជ្ជកម្ម និង ដុល្លារអាមេរិក ។

– បានឃើញសេចក្តីជូនដំណឹងលេខ ០០១ សជណ.កហរ ចុះថ្ងៃទី ០៤ ខែមករា ឆ្នាំ១៩៩០ របស់ក្រសួងហិរញ្ញវត្ថុ ។

– បានឃើញការចាំបាច់ របស់ក្រសួងកសិកម្ម ។

សំរេច

ប្រការ ១ : កំណត់ថ្លៃលក់ឧបករណ៍ និង សម្ភារៈកសិកម្មដូចខាងក្រោម :

ក – ចបកាប់របមាន់ ថ្លៃ ៤០០រ០០ ក្នុងមួយដើម

ខ – បំពង់បាញ់ថ្នាំចំណុះ ១៣ លីត្រ ថ្លៃ ៨.០០០រ០០ ក្នុងមួយគ្រឿង

គ – បំពង់បាញ់ថ្នាំចំណុះ ១៧ លីត្រ ថ្លៃ ៩.០០០រ០០ ក្នុងមួយគ្រឿង

ប្រការ ២ : ចំនួនប្រាក់លំអៀង រវាងអត្រាប្តូរប្រាក់ក្នុងការទូទាត់ជាមួយអង្គភាពប្រគល់ទំនិញទៅឲ្យក្រុមហ៊ុនសម្ភារៈកសិកម្មមជ្ឈិម ត្រូវបង់ចូលថវិកាជាតិទាំងអស់ ។

ប្រការ ៣ : បទបញ្ញត្តិទាំងឡាយណា ដែលមានពីមុនមកហើយមានន័យផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។ សេចក្តីសំរេចនេះ មានប្រសិទ្ធិភាពលើការទូទាត់ថ្លៃចាប់ពីថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៨៩ ដែលមានចេញគំរោងបែងចែកលេខ ៤.៤៦៤-១.៦២០ កសក.ផ.ផក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៨៩ ។

ប្រការ ៤ : មន្ទីរ នាយកដ្ឋានផែនការ ស្ថិតិ នាយកដ្ឋាន គណនេយ្យ-ហិរញ្ញវត្ថុ នាយកដ្ឋានពេទ្យសត្វ ក្រុមហ៊ុនសម្ភារៈកសិកម្មផ្សេងៗ គ្រប់មន្ទីរកសិកម្មខេត្ត-ក្រុង ត្រូវទទួលបន្ទុករៀងៗ ខ្លួនអនុវត្តសេចក្តីសំរេចនេះ ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម

ហត្ថលេខា និង ត្រា

សាយ ឈុំ

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩០.

សេចក្តីសំរេច លេខ០៧៩ សសរ.កសក

ស្តីពីថ្លៃលក់ថ្នាំព្យាបាលសត្វ

រដ្ឋមន្ត្រីក្រសួងកសិកម្ម

– បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

– បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៤ ស្តីពីតួនាទីភារៈកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់ក្រសួងកសិកម្ម ។

– បានឃើញសេចក្តីសំរេចលេខ ១៧៤ សសរ.ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីថានានុក្រមគ្រប់គ្រងថ្លៃ ។

– តាមសំណើរបស់នាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល ។

សំរេច

ប្រការ ១ : កំណត់ថ្លៃលក់ថ្នាំព្យាបាលសត្វ មានដូចខាងក្រោមនេះ ៖

១ - ស៊ីរ៉ូមស្តេ្រប ១០០ មល. ថ្លៃ ៣១០:០០ ក្នុងមួយដប

២ - វីតាមីន អា-ដេ ៣ អឺវេ ១០០ មល. ថ្លៃ ៣៨៦:០០ ក្នុងមួយដប

៣ - មុកស៊ីតេត្រាស៊ីគ្លីន ១០០ គុជ. ថ្លៃ ៨១៨០០ ក្នុងមួយឧប

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានពីមុនមកហើយផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : មន្ទីរ, នាយកដ្ឋាន ផលិតកម្ម និង បសុពេទ្យ នាយកដ្ឋានផែនការ ស្ថិតិ, នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ, មន្ទីរកសិកម្មខេត្ត - ក្រុង ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តសេចក្តីសំរេចនេះ ។

សេចក្តីសំរេចនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម

ហត្ថលេខា និង ត្រា

កោង - ឆុំ

សហគ្រាសសម្ព័ន្ធរោងពុម្ព
បោះពុម្ពនៅរោងពុម្ពសុខាភិបាល
លើកទី ១ ចំនួន ៩.០០០ ច្បាប់